


# អាន និងរៀន
# ដើម្បីកសាងអនាគត

Sipar

## របាយការណ៍សកម្មភាពប្រចាំឆ្នាំ ២០២៣

# មាតិកា

សាររបស់ក្រុមការងារអង្គការស៊ីប៉ានៅប្រទេសកម្ពុជា និងបារាំង ៣
អំពីអង្គការស៊ីប៉ា ៤
កម្មវិធីតាមសាលារៀន ៦
កម្មវិធីអប់រំ និងអំណានសម្រាប់ទាំងអស់គ្នា ៨
កម្មវិធីអភិវឌ្ឍយុវជន ១៤
កម្មវិធីបោះពុម្ពផ្សាយ ១៧
ព្រឹត្តិការណ៍សំខាន់ៗ ២០
សកម្មភាពអប់រំផ្សេងៗ ក្រៅពីសៀវភៅ ២២
ដៃគូរបស់យើង ២៤
សង្ខេបចំណាយប្រចាំឆ្នាំ ២០២៣ ២៥
ផែនការសម្រាប់ឆ្នាំ ២០២៤ ២៦

LABEL IDEAS
L'EXIGENCE
en action

អង្គការស៊ីប៉ាទទួលបានស្លាក IDEAS នៅដើមឆ្នាំ២០២៣។ ការទទួលស្គាល់នេះបញ្ជាក់ពីឧត្តមានុវត្តលើអភិបាលកិច្ច ហិរញ្ញវត្ថុគ្រប់គ្រង និងប្រសិទ្ធភាពសកម្មភាព។

ស៊ីប៉ាដំណើរការដោយអនុលោមតាមគុណតម្លៃជាមូលដ្ឋាននៃការគោរពវប្បធម៌ តម្លាភាព ឯករាជ្យភាពរបស់ប្រជាជន និងការផ្ទេរចំណេះដឹង។ នៅឆ្នាំ ២០២៤ អង្គការស៊ីប៉ានឹងអនុម័តលើការរួមបញ្ចូលសង្គម និងគោលនយោបាយសមភាពយេនឌ័រ ដែលជាគុណតម្លៃមួយរបស់អង្គការស៊ីប៉ា ប៉ុន្តែមិនដែលត្រូវបានអនុវត្តជាផ្លូវការរហូតមកដល់ពេលនេះ។

# សាររបស់ក្រុមការងារអង្គការស៊ីប៉ានៅកម្ពុជា និងបារាំង

អង្គការស៊ីប៉ាបន្តពង្រីកវិសាលភាពនៃសកម្មភាពរបស់ខ្លួននៅឆ្នាំ២០២៣ តាមរយៈការងារដែលដឹកនាំដោយក្រុមការងារនៅភ្នំពេញ គាំទ្រដោយក្រុមប្រឹក្សាភិបាលដែលមានមូលដ្ឋាននៅប្រទេសបារាំង។

ជាង៣៣ឆ្នាំបន្ទាប់ពីជំហានដំបូងរបស់ខ្លួននៅក្នុងសាលារៀនសាធារណៈនៅកម្ពុជា ឆ្នាំនេះ អង្គការស៊ីប៉ាបានបន្តការគាំទ្របណ្តាញបណ្ណាល័យក្នុងសាលារៀន តាមរយៈការបន្តការផ្គត់ផ្គង់សៀវភៅ ជួសជុល និងសាងសង់បណ្ណាល័យថ្មី។ សព្វថ្ងៃនេះ សាលារៀនជាង៣០០ មានបណ្ណាល័យ ដែលសាងសង់ឡើងក្រោមជំនួយពីស៊ីប៉ា និងដាក់ឱ្យសិស្សានុសិស្សប្រើប្រាស់។ អង្គការស៊ីប៉ាក៏ផ្តល់ការបណ្តុះបណ្តាលដល់សាលានីមួយៗលើការគ្រប់គ្រងបណ្ណាល័យ បច្ចេកទេសនិទានរឿង និងការលើកកម្ពស់ការយល់ដឹងបញ្ហាសង្គម និងបរិស្ថាន។

នៅឆ្នាំ២០២៣ បណ្ណាល័យចល័តចំនួន១៤ បានបន្តចរាចរនៅក្នុងខេត្តចំនួន៧ នៃប្រទេសកម្ពុជា និងរាជធានីភ្នំពេញ ( ជាពិសេសនៅតាមតំបន់មិនទាន់រៀបរយតាមជាយក្រុង ) ដើម្បីសម្របសម្រួលសកម្មភាពអំណាន និងអប់រំ។ កម្មវិធីអប់រំនៅតាមឡូតដ្ឋត្រូវបានពង្រីកដល់ឡូតដ្ឋចំនួន៣២។ យើងក៏បានចាប់ផ្តើមរៀបចំដាក់ឱ្យដំណើរការបណ្ណាល័យទូកទីពីរដែរ។ ដើម្បីធានានិរន្តរភាពនៃគម្រោងទាំងនេះ អង្គការស៊ីប៉ាបន្តពង្រឹងបណ្ណាល័យខ្នាតតូចចំនួន៩៥ ដែលបានដាក់ឱ្យប្រើប្រាស់នៅតាមភូមិនានា។

បណ្ណាល័យក្នុងពន្ធនាគារទាំង២៨ ត្រូវបានគ្រប់គ្រងដោយមន្ត្រីពន្ធនាគារផ្ទាល់។ ស៊ីប៉ានៅតែផ្តល់ការគាំទ្រផ្នែកអប់រំដល់ពន្ធនាគារទាំងអស់។ បណ្ណាល័យពន្ធនាគារចំនួន១៥ ត្រូវបានបំពាក់ដោយ NomadLab ដែលជាមន្ទីរពិសោធន៍ឌីជីថលមិនភ្ជាប់បណ្តាញអ៊ីនធឺណិត ដើម្បីបញ្ជ្រាបការអប់រំបែបឌីជីថល គាំទ្រជនជាប់ឃុំ ក្នុងការធ្វើសមាហរណកម្ម និងការអភិវឌ្ឍខ្លួនរបស់ពួកគេ។

ដើម្បីគាំទ្រដល់យុវជនក្នុងការតម្រង់ទិសវិជ្ជាជីវៈ និងការចូលរួមរបស់ពលរដ្ឋក្នុងសហគមន៍ កម្មវិធីអភិវឌ្ឍយុវជន ត្រូវបានពង្រឹងដោយការបង្កើតបណ្ណាល័យចំនួន១៦ រួមមានជ្រុងតម្រង់ទិសនៅតាមអនុវិទ្យាល័យនៅតំបន់ជនបទ និងការគាំទ្រពីសមាជិកយុវជនស្ម័គ្រចិត្តមកពីអង្គការសហគមន៍យុវជនមូលដ្ឋានចំនួន១៥។ ទន្ទឹមនឹងនេះ យើងក៏បានរៀបចំឯកសារណែនាំអំពីអាជីព និងការអភិវឌ្ឍខ្លួនសម្រាប់យុវជន ដែលមានទាំងក្នុងទម្រង់បោះពុម្ព និងបែបឌីជីថល។

ជាចុងក្រោយ ក្រុមការងារបោះពុម្ពផ្សាយបានធ្វើការយ៉ាងសកម្មដើម្បីលើកកម្ពស់ការអាននិងការអប់រំនៅកម្ពុជា តាមរយៈការបោះពុម្ពសៀវភៅថ្មីចំនួន១៩ ក្នុងឆ្នាំ២០២៣ ហើយបច្ចុប្បន្ននេះកាតាឡុករបស់ស៊ីប៉ាមាន២៨៩ចំណងជើងហើយ។

នៅឆ្នាំ២០២៤ ស្របតាមផែនការយុទ្ធសាស្ត្ររបស់ខ្លួន ស៊ីប៉ានឹងបន្ត និងពង្រីកបេសកកម្មក្នុងការលើកកម្ពស់ការអាន និងការអប់រំសម្រាប់ទាំងអស់គ្នា ការគាំទ្រផ្នែកអប់រំ និងការអភិវឌ្ឍយុវជនកម្ពុជានៅក្នុងតំបន់ដែលជួបការលំបាកបំផុត។

ស៊ីប៉ាសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមិត្តរួមការងារ ដៃគូសហការ និងម្ចាស់ជំនួយទាំងអស់ ដែលនៅតែបន្តផ្តល់ការគាំទ្រដល់ពួកយើងក្នុងបុព្វហេតុអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា។

ក្រុមការងារអង្គការស៊ីប៉ានៅកម្ពុជា និងបារាំង

# អំពីអង្គការស៊ីប៉ា

## អាន និងរៀនដើម្បីកសាងអនាគត

អង្គការស៊ីប៉ាគឺជាអង្គការសាមគ្គីភាពអន្តរជាតិ ដែលបង្កើតឡើងដំបូងក្នុងឆ្នាំ១៩៨២ នៅប្រទេសបារាំង ដើម្បីស្វាគមន៍ជនភៀសខ្លួនមកពីប្រទេសអាស៊ីអាគ្នេយ៍ ហើយបានចាប់ផ្តើមធ្វើការក្នុងវិស័យអប់រំនៅកម្ពុជាតាំងពីឆ្នាំ១៩៩១។ អង្គការស៊ីប៉ារួមចំណែកយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងនឹងអនក្ខរភាព និងចូលរួមអភិវឌ្ឍវិស័យអំណានសម្រាប់ទាំងអស់គ្នា តាមរយៈការពង្រឹងបណ្តាញបណ្ណាល័យចល័ត និងអចល័ត នៅតាមសាលារៀន សហគមន៍ជនបទ តំបន់ជាយក្រុងភ្នំពេញ រោងចក្រកាត់ដេរ ឡូតដ្ឋ មន្ទីរពេទ្យ និងពន្ធនាគារជាដើម។ ដោយមានកិច្ចសហការយ៉ាងល្អជាមួយក្រសួងអប់រំ យុវជន និងកីឡា អជ្ញាធរមូលដ្ឋាន និងសហគមន៍ សមាគមក្នុងស្រុក និងអន្តរជាតិ អង្គការស៊ីប៉ាបានធ្វើការផ្សព្វផ្សាយ និងចែកចាយសៀវភៅទូទាំងប្រទេស តាមរយៈការអនុវត្តកម្មវិធីប្រកបដោយភាពច្នៃប្រឌិត។

លើសពីនេះ ដោយឃើញភាពទន់ខ្សោយនៃវិស័យបោះពុម្ពផ្សាយនៅកម្ពុជា និងកង្វះខាតសៀវភៅអាន អង្គការស៊ីប៉ាបានពង្រីកបេសកកម្មរបស់ខ្លួននៅឆ្នាំ២០០០ ដោយបង្កើតកម្មវិធីបោះពុម្ពផ្សាយសៀវភៅជាភាសាខ្មែរសម្រាប់កុមារ យុវវ័យ និង មនុស្សពេញវ័យ។ ស៊ីប៉ាកំពុងរួមចំណែកយ៉ាងសកម្មក្នុងការលើកកម្ពស់លទ្ធភាពទទួលបានចំណេះដឹង ការអប់រំ និងជួយដល់កុមារក្នុងការរៀនអក្សរនៅក្នុងបរិបទនៃកម្ពុជាដែលមានអនក្ខរជនជិត១៦%។




### កម្មវិធីក្នុងសាលារៀន

- បណ្ណាល័យសាលារៀនមានចំនួន៣១៨ នៅទូទាំង២៥រាជធានីខេត្ត

### អំណានសម្រាប់ទាំងអស់គ្នា

- រថយន្តបណ្ណាល័យចល័តចំនួន១៤ ធ្វើសកម្មភាពនៅតាមទីតាំងចំនួន១២៦ ក្នុងរាជធានីខេត្តចំនួន៧ ៖ ដោយមានរថយន្តបណ្ណាល័យចល័តចំនួន៩ បណ្ណាល័យតុកតុកចំនួន៣ បណ្ណាល័យទូកចំនួន១ និងបណ្ណាល័យម៉ូតូចំនួន១
- បណ្ណាល័យចំនួន២៨ ដំណើរការក្នុងពន្ធនាគារ និងមណ្ឌលអប់រំកែប្រែនៅក្នុងខេត្តចំនួន២៥ រួមទាំងក្នុងរាជធានីភ្នំពេញ
- បណ្ណាល័យមណ្ឌលសិក្សាសម្រាប់កម្មករ កម្មការិនីរោងចក្រកាត់ដេរចំនួន២៥ កំពុងដំណើរការក្នុងខេត្តចំនួន៨ រួមទាំងរាជធានីភ្នំពេញ
- បណ្ណាល័យខ្នាតតូចចំនួន៧៤ នៅតាមផ្ទះអ្នកស្ម័គ្រចិត្តនៅតំបន់ជនបទ មត្តេយ្យសិក្សា និងសាលាបឋមសិក្សា

### កម្មវិធីការងារស្ម័គ្រចិត្តរបស់យុវជនដើម្បីការអភិវឌ្ឍសហគមន៍

- បណ្ណាល័យ និងជ្រុងតម្រង់ទិសវិជ្ជាជីវៈចំនួន១៦
- អង្គការសហគមន៍យុវជនមូលដ្ឋាន ចំនួន១៨ នៅខេត្តព្រៃវែង និងក្រចេះ
- បណ្ណាល័យខ្នាតតូចចំនួន២១ ដែលគ្រប់គ្រងដោយយុវជនស្ម័គ្រចិត្ត

### កម្មវិធីបោះពុម្ពផ្សាយ

- សៀវភៅថ្មីចំនួន១៩ ចំណងជើងក្នុងឆ្នាំ២០២៣ ដែលសរុបមាន២៨៩ចំណងជើងចាប់ពីឆ្នាំ២០០១
- សៀវភៅសរុប ៣លាន ៣សែនក្បាលចាប់ពីឆ្នាំ២០០១
- វគ្គបណ្តុះបណ្តាលចំនួន៨៥ចាប់ពីឆ្នាំ២០០៤មក

៤០ ឆ្នាំនៃសកម្មភាព

បុគ្គលិកខ្មែរសរុប ចំនួន ៦៣ នាក់ (ស្ត្រី ៣០ នាក់)

សមាជិក ក្រុមប្រឹក្សាភិបាល ១២ នាក់

គ្របដណ្តប់ទូទាំង ២៥ រាជធានី ខេត្ត

អ្នកទទួលផល +៣៦០ ០០០ នាក់ តាមរយៈ ៦៣០ បណ្ណាល័យ

## ចក្ខុវិស័យ

ប្រជាជនកម្ពុជាមានការអប់រំ គឺជាតួអង្គចាំបាច់ក្នុងការបន្តអភិវឌ្ឍប្រទេសប្រកបដោយនិរន្តរភាព និងស្វ័យភាព។

## បេសកកម្ម

ចូលរួមចំណែកក្នុងការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា ជាពិសេសសម្រាប់ជនដែលគ្មានឱកាស តាមរយៈការផ្សព្វផ្សាយការអាន និងវិធីដទៃទៀតក្នុងការទទួលបានចំណេះដឹង និងការអប់រំ។

## គុណតម្លៃ

- ឯករាជ្យ
- តម្លាភាព
- គោរពបុគ្គល និងវប្បធម៌ចម្រុះ
- ការផ្ទេរចំណេះដឹង
- នវានុវត្តន៍
- ស្វ័យភាព

## សកម្មភាពរបស់អង្គការស៊ីប៉ាចែកជា៤កម្មវិធីសំខាន់ៗ ៖



**កម្មវិធី តាមសាលារៀន**



**កម្មវិធីអប់រំ និងអំណាន សម្រាប់ទាំងអស់គ្នា**



**កម្មវិធី អភិវឌ្ឍយុវជន**




**កម្មវិធី បោះពុម្ពផ្សាយ**




*គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៃអង្គការសហប្រជាជាតិ ៣ ដែលអង្គការស៊ីប៉ាផ្តោតសកម្មភាពគឺ ៖*

- ៤ ៖ ការអប់រំប្រកបដោយគុណភាព
- ១០ ៖ កាត់បន្ថយវិសមភាព
- ១៧ ៖ ភាពជាដៃគូដើម្បីសម្រេចគោលដៅ

**យើងក៏បានចូលរួមចំណែកសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពផ្សេងទៀតដែរ តាមរយៈកម្មវិធីផ្សេងៗរួមមាន ៖**

- ៣ ៖ សុខភាព និងសុខុមាលភាពមាំមួន (តាមរយៈកម្មវិធីអប់រំសុខភាព)
- ៥ ៖ សមភាពយេនឌ័រ (កម្មវិធីគាំទ្រការងារស្ម័គ្រចិត្តរបស់យុវជន និងកម្មវិធីអប់រំស៊ីម)
- ៨ ៖ ការងារសមរម្យ និងកំណើនសេដ្ឋកិច្ច (កម្មវិធីបណ្ណាល័យក្នុងរោងចក្រ)
- ១២ ៖ ការប្រើប្រាស់ និងការផលិតប្រកបដោយទំនួលខុសត្រូវ (តាមរយៈកម្មវិធីអប់រំបរិស្ថាន)
- ១៦ ៖ សន្តិភាព យុត្តិធម៌ និងស្ថាប័នដ៏រឹងមាំ (កម្មវិធីបណ្ណាល័យក្នុងពន្ធនាគារ)



គាំទ្រការអនុវត្តគោលនយោបាយជាតិសម្រាប់បណ្ណាល័យនៅតាមសាលារៀនទាំងបីកម្រិត ៖ មត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា។

# កម្មវិធី តាមសាលារៀន

© Laurent Jannic



# កម្មវិធីតាមសាលារៀន

*បរិបទ ៖ នៅឆ្នាំ១៩៩៣ អង្គការស៊ីប៉ាបានចាប់ផ្តើមកម្មវិធីបណ្ណាល័យសាលារៀន ដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងសកម្មភាពបីគឺ ៖ អភិវឌ្ឍបណ្តាញបណ្ណាល័យចំនួន៣០០នៅសាលាបឋមសិក្សា ផ្តល់ជំនួយបណ្តុះបណ្តាលបច្ចេកទេសដល់បណ្ណាល័យសាលារៀន និងចុងក្រោយ ផ្តល់ការបណ្តុះបណ្តាលដល់បណ្ណារក្ស។ គម្រោងនេះបានអភិវឌ្ឍ និងរីកចម្រើន ដែលឈានទៅដល់ការធ្វើស្ថាប័នភាវូបនីយកម្ម ទៅកម្រិតថ្នាក់ជាតិ ដោយជួយគាំទ្រដល់ការអនុវត្តគោលនយោបាយបណ្ណាល័យសាលារៀនមត្តេយ្យ បឋម និងមធ្យមសិក្សា។*

គាំទ្រការអានសម្រាប់កុមារតូច ៖ បណ្ណាល័យខ្នាតតូចថ្មីចំនួនបីនៅក្នុងសាលាមត្តេយ្យត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០២៣។ បណ្ណាល័យខ្នាតតូចសរុបចំនួន១៨ នៅក្នុងសាលាមត្តេយ្យត្រូវបានដាក់ឱ្យប្រើប្រាស់។ បណ្ណាល័យទាំងនេះបើកទ្វារជាសាធារណៈដើម្បីទទួលសមាជិកនៅសហគមន៍មូលដ្ឋាន មកអាន និងខ្ចីសៀវភៅបាន។ គ្រូបង្រៀននៅក្នុងសាលាមត្តេយ្យសហគមន៍ និងអ្នកគ្រប់គ្រងស្ម័គ្រចិត្តនៃបណ្ណាល័យខ្នាតតូចបានទទួលការបណ្តុះបណ្តាល និងគាំទ្រដោយក្រុមបណ្ណារក្សចល័តរបស់យើងក្នុងការគ្រប់គ្រង និងការរៀបចំសកម្មភាពសម្រាប់បណ្ណាល័យទាំងនេះ។

យើងបន្តពង្រឹងភាពទាក់ទាញនៃបណ្ណាល័យបឋមសិក្សាដែលជាដៃគូផងដែរ។ ចាប់តាំងពីឆ្នាំ២០១៩ ស៊ីប៉ាបានផ្តល់សៀវភៅថ្មីចំនួន ១០០ក្បាលដល់បណ្ណាល័យនីមួយៗ ដើម្បីបំពេញតម្រូវការអ្នកអានវ័យក្មេង។ ដោយមានការគាំទ្រពីម្ចាស់ជំនួយជាច្រើន យើងបានផ្តល់សៀវភៅដល់សាលាចំនួន៤៤ នៅឆ្នាំ២០២៣។ យើងក៏បានបង្កើតបណ្ណាល័យខ្នាតតូចថ្មីចំនួន១០ ដែលផ្តល់សេវាដល់អ្នកភូមិ។

ស៊ីប៉ាក៏ផ្តល់ជំនួយដល់សាលាមធ្យមសិក្សាផងដែរ។ នៅខែកក្កដា ឆ្នាំ២០២៣ ក្រុមការងាររបស់យើងបានជួសជុលអគារ និងបង្កើតបណ្ណាល័យថ្មីនៅអនុវិទ្យាល័យអង្គរជ័យ ក្នុងស្រុកអង្គរជ័យ ខេត្តកំពត។ សៀវភៅជាង ១២០០ក្បាល និងឧបករណ៍គ្រប់គ្រងបណ្ណាល័យត្រូវបានដាក់ឱ្យប្រើប្រាស់។ លើសពីនេះ អង្គការស៊ីប៉ាបានគាំទ្រដល់ការបង្កើតបណ្ណាល័យនៅវិទ្យាល័យជាស៊ីមអង្គរជ័យ ដោយផ្តល់ឧបករណ៍ និងសៀវភៅជាង ២៥០០ក្បាល។






*"ដោយមានការគាំទ្ររបស់អង្គការស៊ីប៉ា សិស្សរបស់យើងបានចាប់ផ្តើមចូលចិត្តការអានសៀវភៅ និងប្រើប្រាស់បណ្ណាល័យគួរឱ្យកត់សម្គាល់។ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អង្គការស៊ីប៉ា សម្រាប់ការលើកកម្ពស់ការអាននៅក្នុងសាលារបស់យើង!"*

**លោកស្រី លាន ថាវី**
មន្ត្រីនាយកដ្ឋានមធ្យមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា



គាំទ្រដល់ប្រជាជនដែលជួបការលំបាក បង្កើតទម្លាប់អាន ដោយពង្រីកឱកាសទទួលបានសៀវភៅ ព័ត៌មាន និងការអប់រំ ដែលជាកត្តាចាំបាច់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។

# កម្មវិធីអប់រំ និងអំណានសម្រាប់ទាំងអស់គ្នា




# បណ្ណាល័យចល័ត

***បរិបទ ៖*** *លទ្ធភាពទទួលបានសៀវភៅ និងចំណេះដឹងសម្រាប់សហគមន៍នៅជាយក្រុងភ្នំពេញ និងជនបទនៅមានកម្រិតនៅឡើយ ដោយខ្វះហេដ្ឋារចនាសម្ព័ន្ធអប់រំ ដូចជាបណ្ណាល័យសាធារណៈជាដើម។ ចាប់តាំងពីឆ្នាំ ២០០០ មក កម្មវិធីបណ្ណាល័យចល័តរបស់ស៊ីប៉ាបានចាប់ផ្តើមដំណើការដោយនាំយកសកម្មភាពអំណាន សំណេរ និងសៀវភៅទៅឱ្យកុមារខ្លី ព្រមទាំងមានការគាំទ្រផ្នែកអប់រំ និងការលើកកម្ពស់ការយល់ដឹងអំពីបញ្ហាសង្គមសំខាន់ៗ។*

បណ្ណាល័យចល័តស៊ីប៉ាទាំង ១៤ រួមមានបណ្ណាល័យរថយន្តចំនួនប្រាំបួន បណ្ណាល័យតុកតុកចំនួនបី បណ្ណាល័យទូកចំនួនមួយ និងបណ្ណាល័យម៉ូតូចំនួនមួយ។ បណ្ណាល័យចល័តទាំង ១៤ នេះកំពុងធ្វើសកម្មភាពនៅតាមទីតាំងជាង ១២៦ កន្លែងជារៀងរាល់សប្តាហ៍ នៅតាមខេត្តចំនួន៧នៅកម្ពុជា និងបានផ្តល់ផលដល់អ្នកអានជាង ១៦ ០០០នាក់។ សកម្មភាពទូទៅរបស់បណ្ណាល័យចល័តចាប់ផ្តើមដោយអំណាន (ការនិទានរឿង និងអំណានសេរី) ល្បែងអប់រំ និងច្នៃប្រឌិត និងបញ្ចប់ដោយការខ្ចីសងសៀវភៅ។ ថ្មីៗនេះ ក្រុមការងាររបស់បណ្ណាល័យចល័តបានរៀបចំថ្នាក់បំប៉នរៀងរាល់សប្តាហ៍ លើមុខវិជ្ជាសំខាន់ៗរបស់សាលា ៖ ភាសាខ្មែរ និងគណិតវិទ្យា។

ក្រុមការងាររបស់យើងក៏រៀបចំវគ្គយល់ដឹងប្រធានបទសំខាន់ៗ ដូចជា សុខភាព និងអាហារូបត្ថម្ភ សុវត្ថិភាពចរាចរណ៍ ការអប់រំកម្មវិធីបរិយាបន្នសម្រាប់អ្នករស់នៅជាមួយពិការភាព យេនឌ័រ និងសមាធិ បរិស្ថាន និងស្ទីម (STEAM) - វិទ្យាសាស្រ្ត បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និងគណិតវិទ្យា។ នៅឆ្នាំ២០២៣ ក្រុមការងារបណ្ណាល័យចល័តបានរៀបចំវគ្គឯកទេសលើប្រធានបទទាំងនេះជាង៣០០វគ្គ ដើម្បីលើកកម្ពស់ការយល់ដឹងក្នុងចំណោមកុមារ ក្មេងជំទង់ និងមនុស្សពេញវ័យជាង ៨០០០នាក់។

ដើម្បីធានាបាននូវនិរន្តរភាពនៃបេសកកម្មរបស់ខ្លួន ស៊ីប៉ាបានបង្កើតបណ្ណាល័យខ្នាតតូចនៅតាមភូមិដែលបណ្ណាល័យចល័តរបស់យើងបានដំណើរការអស់រយៈពេលជាច្រើនឆ្នាំ ដោយធ្វើការយ៉ាងជិតស្និទ្ធជាមួយអ្នកស្ម័គ្រចិត្តក្នុងសហគមន៍។ បណ្ណាល័យខ្នាតតូចចំនួន៧៤ ដែលមានសៀវភៅសរុបចំនួន ៣០ ០០០ក្បាល ត្រូវបានដាក់ឱ្យដំណើរការ និងគ្រប់គ្រងដោយអ្នកស្ម័គ្រចិត្តក្នុងសហគមន៍។ តាមរយៈសកម្មភាពនៅតាមបណ្ណាល័យខ្នាតតូចទាំងនេះ បណ្ណាល័យចល័តស៊ីប៉ាអាចកាត់បន្ថយការធ្វើដំណើរ ហើយចាប់ផ្តើមធ្វើសកម្មភាពនៅក្នុងភូមិថ្មីៗ។ ក្រុមការងារស៊ីប៉ាផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់អ្នកស្ម័គ្រចិត្តទាំងអស់។



*"មិត្តម្នាក់បានណែនាំខ្ញុំឱ្យស្គាល់បណ្ណាល័យចល័តរបស់ស៊ីប៉ា ហើយខ្ញុំបានចូលរួមអស់រយៈពេលបួនឆ្នាំមកហើយ។ ខ្ញុំអាចអាន និងសរសេរកាន់តែប្រសើរ ដោយមានការអនុវត្តជាមួយសៀវភៅដែលស៊ីប៉ាផ្តល់ឱ្យ។"*

**កែវ សកុណា**
អាយុ១២ឆ្នាំ សិស្សថ្នាក់ទី៦

រថយន្តបណ្ណាល័យចល័ត ៩

បណ្ណាល័យតុកតុក ចល័ត ៣

បណ្ណាល័យម៉ូតូ ចល័ត ១

បណ្ណាល័យទូក ចល័ត ១

អ្នកទទួលផល ១៦ ៥០០នាក់

១២៦ ទីតាំង

បណ្ណាល័យខ្នាតតូច ៧៤



# បណ្ណាល័យចល័តសម្រាប់ប្រជាជនងាយរងគ្រោះ

***បរិបទ*** *៖ ប្រជាជនកម្ពុជាប្រមាណ ១៦.៦% រស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រ ពោលគឺតិចជាងពីរដុល្លារកន្លះក្នុងមួយថ្ងៃសម្រាប់មនុស្សម្នាក់។ ប្រជាជនកម្ពុជាក្រីក្រភាគច្រើនរស់នៅក្នុងតំបន់មិនទាន់រៀបរយតាមជាយក្រុងភ្នំពេញ និងនៅតំបន់ជនបទ តំបន់បឹងទន្លេសាប និងតំបន់ភ្នំដែលមានអត្រាភាពក្រីក្រខ្ពស់បំផុត។ ដើម្បីលើកកម្ពស់អំណានសម្រាប់ទាំងអស់គ្នា ស៊ីប៉ាផ្តោតលើការជួយដល់ការអប់រំ និងការអភិវឌ្ឍការអានក្នុងចំណោមប្រជាជនដែលងាយរងគ្រោះ។*

**ជនជាតិភាគតិច ៖** ចាប់តាំងពីឆ្នាំ ២០១៣ មក អង្គការស៊ីប៉ាបានធ្វើការជាមួយជនជាតិភាគតិចទំពួន និងចារ៉ាយ ក្នុងខេត្តរតនគិរី ដើម្បីលើកកម្ពស់ការអាន និងផ្តល់ការគាំទ្រផ្នែកអប់រំដល់កុមារ។ បណ្ណាល័យចល័តតុកតុក ដែលបំពាក់ដោយសៀវភៅ និងល្បែងអប់រំ កំពុងចរាចរនៅក្នុងភូមិដាច់ស្រយាលទាំង១២ នៃស្រុកបរកែវ។ សកម្មភាពអំណាន និងអប់រំ ត្រូវបានរៀបចំដោយបណ្ណារក្សដែលចេះពីរភាសា ខ្មែរ-ទំពួន ដែលផ្តល់ការគាំទ្រយ៉ាងសំខាន់ដល់កុមារ ដើម្បីពង្រឹងការសិក្សារបស់ពួកគេជាភាសាខ្មែរ។

**នៅតាមឡឥដ្ឋ ៖** អង្គការស៊ីប៉ាបានផ្តួចផ្តើមគម្រោងដំបូងសម្រាប់ការអភិវឌ្ឍអំណាន និងការប្រយុទ្ធប្រឆាំងនឹងអនក្ខរភាពក្នុងចំណោមគ្រួសារកម្មករនៅតាមឡឥដ្ឋក្នុងឆ្នាំ២០១៨។ ឡឥដ្ឋនីមួយៗមានគ្រួសាររស់នៅជាមធ្យមចំនួន៤០ និងមានប្រជាជនសរុបជាមធ្យមប្រមាណ ១៥០នាក់ ដែលក្នុងនោះ ៥០ នាក់មានអាយុក្រោម ១៨ ឆ្នាំ។ គ្រួសារកម្មករទាំងនេះរស់នៅក្នុងភាពក្រីក្រខ្លាំង ហើយកុមារមានលទ្ធភាពទទួលបានការសិក្សាតិចតួចបំផុត។ ក្នុងឆ្នាំ២០២៣ តាមរយៈការគាំទ្រពីដៃគូរបស់យើង និងការផ្តល់មូលនិធិពីទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ ស៊ីប៉ាអាចពង្រីកសកម្មភាពរបស់ខ្លួនជាមួយនឹងបណ្ណាល័យចល័តចំនួន៤ ទៅដល់ឡឥដ្ឋចំនួន៣២ ( សូមមើលព័ត៌មានលម្អិតនៅក្នុងអត្ថបទការអប់រំនៅតាមឡឥដ្ឋ )។

**នៅតំបន់មិនទាន់រៀបរយតាមជាយក្រុងភ្នំពេញ ៖** យើងជួយដល់គ្រួសារដែលរស់នៅក្នុងស្ថានភាពមិនច្បាស់លាស់ ក្នុងតំបន់មិនទាន់រៀបរយតាមជាយក្រុងភ្នំពេញ។ ប្រជាជនទាំងនេះមានលទ្ធភាពតិចតួចក្នុងការទទួលបានការអប់រំ និងសេវាសុខភាព ដែលជាហេតុឱ្យជួបប្រទះនឹងអត្រាអនក្ខរភាពខ្ពស់។ ដើម្បីគាំទ្រដល់ប្រជាជននៅតំបន់មិនទាន់រៀបរយតាមជាយក្រុងភ្នំពេញ អង្គការស៊ីប៉ាបានដាក់ឱ្យដំណើរការបណ្ណាល័យតុកតុកពីរ ហើយបណ្ណាល័យតុកតុកមួយ បានសហការជាមួយអង្គការ Planète Enfants & Développement។ បណ្ណាល័យតុកតុកទាំងពីរត្រូវបានដាក់ឱ្យដំណើរការ សម្រាប់បម្រើដល់តំបន់មិនទាន់រៀបរយចំនួន១៤ និងសាលាអប់រំពិសេសចំនួនពីរ ដើម្បីលើកកម្ពស់អំណាន ផ្តល់ការគាំទ្រផ្នែកអប់រំ និងលើកកម្ពស់ការយល់ដឹងអំពីបញ្ហាសង្គម។

**នៅតាមមាត់បឹង និងភូមិបណ្តែតទឹក ៖** ក្នុងចំណោមប្រជាជននេះ កុមារមួយភាគបួនមិនបានទៅសាលាដោយសារខ្វះមធ្យោបាយធ្វើដំណើរ។ អង្គការស៊ីប៉ាបានដាក់ឱ្យដំណើរការបណ្ណាល័យទូកដំបូងបំផុតនៅលើបឹងទន្លេសាបក្នុងឆ្នាំ២០១៩ សម្រាប់អ្នករស់នៅលើបឹង និងភូមិបណ្តែតទឹកដែលមានភាពដាច់ស្រយាល និងពិបាកធ្វើដំណើរ។ បណ្ណាល័យទូកធ្វើសកម្មភាពរៀងរាល់សប្តាហ៍ក្នុងភូមិគោលដៅចំនួនបី និងភូមិជាប់គ្នាចំនួនបីក្នុងឃុំផ្លូវទូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ដើម្បីជួយដល់ការរៀនសូត្រ និងអភិវឌ្ឍទម្លាប់អាន។ បណ្ណាល័យទូកទីពីរនឹងត្រូវដាក់ឱ្យដំណើរការនៅដើមឆ្នាំ២០២៤ ដើម្បីបម្រើប្រជាពលរដ្ឋដែលរស់នៅតាមដងទន្លេសែន មាត់ទន្លេសាប ក្នុងឃុំផាត់សណ្តាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដោយមានការគាំទ្រពីក្រុមហ៊ុន All Dreams Cambodia និង Brousse DELL'AQUILLA funds ដោយសហការជាមួយ Marins Sans Frontières និងដៃគូក្នុងស្រុករបស់យើង។




# ការអប់រំនៅតាមឡឥដ្ឋ

***បរិបទ ៖*** *ការរស់នៅ និងលក្ខខណ្ឌការងារក្នុងឡឥដ្ឋមានការលំបាកយ៉ាងខ្លាំង។ គ្រួសារកម្មករស្ទើរតែទាំងអស់ជំពាក់បំណុលគេច្រើន ហើយបានសុំថៅកែឡឥដ្ឋជួយសងបំណុលគេ។ កម្មករ និងគ្រួសាររបស់គាត់ ស្ថិតក្នុងស្ថានភាពពឹងផ្អែកទៅលើថៅហ្វាយរបស់ពួកគាត់ជួនកាលច្រើនជំនាន់។ ដូច្នេះ ប្រជាជនទាំងនេះងាយរងគ្រោះខ្លាំង ជាពិសេសកុមារ យុវជន និងស្ត្រី។*

អង្គការស៊ីប៉ាបានចាប់ផ្តើមធ្វើការនៅតាមឡឥដ្ឋក្នុងឆ្នាំ២០១៨ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍអប់រំសង្គមរបស់កម្មករ និងកូនៗរបស់ពួកគេនៅជាយក្រុងភ្នំពេញ។ ដោយមានការគាំទ្រពីដៃគូរបស់យើង បណ្ណាល័យចល័តទីមួយចាប់ផ្តើមសកម្មភាពនៅតាមឡឥដ្ឋចំនួន៤ បន្ទាប់មកបណ្ណាល័យចល័តទីពីរធ្វើសកម្មភាពនៅតាមឡឥដ្ឋបួនផ្សេងទៀត។ នៅឆ្នាំ២០២២ ក្រុមការងាររបស់យើងបានរកឃើញឡឥដ្ឋថ្មីចំនួន៤ ដើម្បីពង្រីកសកម្មភាពទៅកាន់អ្នកទទួលផលថ្មី។

នៅខែតុលា ឆ្នាំ២០២៣ អង្គការស៊ីប៉ាទទួលបានការគាំទ្រពីទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ ដោយមានការរួមចំណែកពី មូលនិធិ Luciole និងមូលនិធិ Comgest ដើម្បីពង្រីកសកម្មភាពដល់ឡឥដ្ឋសរុបចំនួន ៣២ ដែលមានប្រមាណ ១៣០០គ្រួសារ ក្នុងស្រុកមុខកំពូល ខេត្តកណ្តាល។ គម្រោងនេះមានគោលបំណងរៀបចំ និងផ្តល់សកម្មភាពអភិវឌ្ឍន៍អប់រំសង្គម ដើម្បីរួមចំណែកលើកកម្ពស់គុណភាពជីវិតគ្រួសារ និងបើកទស្សនៈថ្មីសម្រាប់កុមារ និងយុវជន។

គម្រោងនេះផ្តល់នូវសកម្មភាពមួយចំនួន សម្រាប់ប្រជាជនទាំងមូលនៃឡឥដ្ឋគោលដៅ ៖

- សកម្មភាពបណ្ណាល័យចល័តចំនួន៤ (បណ្ណារក្ស-អ្នកអប់រំ២នាក់ក្នុងបណ្ណាល័យចល័តនីមួយៗ) នៅតាមឡឥដ្ឋចំនួន៣២ ដែលមានកុមារជាង ១៣០០នាក់ ដើម្បីរៀបចំសកម្មភាពអប់រំក្រៅប្រព័ន្ធ និងអំណានប្រចាំសប្តាហ៍។
- ការគាំទ្រការអប់រំរបស់កុមារដែលមានអាយុពី៦ ទៅ១៤ឆ្នាំ ដោយគាំទ្រការចុះឈ្មោះរបស់ពួកគេនៅក្នុងសាលារដ្ឋនៅជិតឡឥដ្ឋ។
- ការគាំទ្របណ្ណាល័យនៅក្នុងសាលាបឋមសិក្សានៅក្បែរឡឥដ្ឋ និងបណ្ណាល័យខ្នាតតូចចំនួន២០ ដែលបានបង្កើតឡើងនៅក្នុងសហគមន៍ជុំវិញឡឥដ្ឋ។
- ការបង្កើតកម្មវិធីសម្រាប់ក្មេងជំទង់អាយុពី១២ ទៅ១៧ឆ្នាំ ដែលបានបោះបង់ការសិក្សា ដើម្បីគាំទ្រដល់ការអភិវឌ្ឍអប់រំសង្គមរបស់ពួកគេ។
- ការរៀបចំវគ្គបណ្តុះបណ្តាលលើប្រធានបទសង្គមដោយក្រុមការងារសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងការអភិវឌ្ឍ ដែលជាដៃគូក្នុងស្រុករបស់យើង និងការចាប់ផ្តើមបញ្ជ្រាបគំនិតផ្តួចផ្តើមទៅដល់អ្នកគ្រប់គ្រង និងថៅកែឡឥដ្ឋ ដើម្បីបង្កើនគុណភាពជីវិតរបស់គ្រួសារកម្មករ។



*“នេះជាលើកទីមួយហើយដែលខ្ញុំបានចូលរួមក្នុងកម្មវិធីបែបនេះ។ ខ្ញុំពេញចិត្តសកម្មភាពនេះណាស់ ព្រោះបណ្ណារក្សជួយខ្ញុំពង្រឹងការអាន និងការសរសេរ ហើយខ្ញុំមានឱកាសអានសៀវភៅថ្មីៗជាច្រើន។ ខ្ញុំចូលចិត្តសៀវភៅ ហើយជារឿយៗខ្ញុំចែករំលែកសៀវភៅជាមួយអ្នកជិតខាង និងមិត្តរួមថ្នាក់របស់ខ្ញុំ ដើម្បីអានជាមួយគ្នា។”*

**សុភស្ស័ រក្សា**
អាយុ១៣ឆ្នាំ អ្នកទទួលផលពីស៊ីប៉ា



# កម្មវិធីអប់រំក្នុងពន្ធនាគារ

***បរិបទ ៖*** *ទណ្ឌិតភាគច្រើនមកពីមជ្ឈដ្ឋានដែលជួបការលំបាក ឬមិនមានឱកាស ការអប់រំមានកម្រិត និងស្ថានភាពសេដ្ឋកិច្ចសង្គមទាប និងមិនមានជំនាញវិជ្ជាជីវៈត្រឹមត្រូវ។ ទោះបីជាមានការកើនឡើងនៃសេវាកម្មដែលផ្តល់ដោយរដ្ឋាភិបាលក៏ដោយ ប៉ុន្តែឱកាសដើម្បីអភិវឌ្ឍការអប់រំ និងធ្វើសមាហរណកម្មចូលសង្គមសម្រាប់ទណ្ឌិតនៅមានកម្រិតនៅឡើយ។*

ស៊ីប៉ាបានចាប់ផ្តើមធ្វើការនៅក្នុងពន្ធនាគារក្នុងឆ្នាំ២០១១ តាមរយៈគម្រោងសាកល្បងនៅក្នុងពន្ធនាគារចំនួន៤ ដើម្បីបំពាក់បណ្ណាល័យ និងលើកកម្ពស់ការអានក្នុងចំណោមអ្នកជាប់ឃុំ។ គម្រោងនេះបានដំណើរការមកជាង៩ឆ្នាំដោយមានការគាំទ្រពីទីភ្នាក់ងារបារាំងដើម្បីអភិវឌ្ឍន៍ ហើយបន្ទាប់មក ពីមូលនិធិ Bellon ។ ជាលទ្ធផល ពន្ធនាគារទាំងអស់នៅកម្ពុជាមានបណ្ណាល័យដំណើរការ រួមជាមួយកម្មវិធីអប់រំបណ្តុះបណ្តាល និងសមាហរណកម្ម។

**ការអភិវឌ្ឍបណ្តាញបណ្ណាល័យពន្ធនាគារទូទាំងប្រទេស ៖** ពន្ធនាគារនីមួយៗនៅប្រទេសកម្ពុជាត្រូវបានបំពាក់ដោយបណ្ណាល័យ ដែលមានកម្មវិធីគ្រប់គ្រងឌីជីថលដោយប្រើកម្មវិធី PMB ។ បណ្ណាល័យទាំង២៨ ត្រូវបានគ្រប់គ្រងដោយពន្ធនាគារនីមួយៗចាប់តាំងពីឆ្នាំ២០២១ ដោយមានការគាំទ្រពីអគ្គនាយកដ្ឋានពន្ធនាគារ។ ជារៀងរាល់ខែ ជនជាប់ឃុំចំនួន ១០ ០០០នាក់ បានប្រើប្រាស់បណ្ណាល័យដើម្បីអាននៅនឹងកន្លែង និងខ្ចីសៀវភៅដើម្បីអាននៅក្នុងបន្ទប់របស់ពួកគេ។ ស៊ីប៉ាបានពង្រឹងជំនាញរបស់បណ្ណារក្ស តាមរយៈការបណ្តុះបណ្តាលពួកគេក្នុងការគ្រប់គ្រងបណ្ណាល័យ និងការប្រើប្រាស់កម្មវិធីកុំព្យូទ័រ។

**ថ្នាក់អក្ខរកម្ម ៖** នាយកដ្ឋានអប់រំក្រៅប្រព័ន្ធនៃក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តគោលនយោបាយជាតិសម្រាប់អក្ខរកម្មក្នុងពន្ធនាគារ។ ស៊ីប៉ាគាំទ្រកម្មវិធីនេះដោយផ្តល់ការគាំទ្រផ្នែកគរុកោសល្យដល់គ្រូបណ្តុះបណ្តាល និងគ្រូបង្រៀនដែលជាមន្ត្រីពន្ធនាគារ និងជំនួយជាសម្ភារៈដល់សិស្ស។ នៅឆ្នាំ២០២៣ ថ្នាក់អក្ខរកម្មចំនួន៤២ បានផ្តល់អត្ថប្រយោជន៍ដល់ជនជាប់ឃុំចំនួន ១០៥០នាក់។

**សមាហរណកម្មសង្គម-វិជ្ជាជីវៈ ៖** អង្គការស៊ីប៉ាបានសហការជាមួយដៃគូអង្គការក្រៅរដ្ឋាភិបាលមួយចំនួន ដើម្បីបង្កើតកម្មវិធីសមាហរណកម្មសង្គម-វិជ្ជាជីវៈសម្រាប់ជនជាប់ឃុំ។ នៅឆ្នាំ២០២៣ អង្គការស៊ីប៉ាបានកែសម្រួលវិធីសាស្ត្ររបស់ខ្លួនដោយការពង្រឹងសមត្ថភាពមន្ត្រីពន្ធនាគារ និងសម្របសម្រួលទំនាក់ទំនង និងកិច្ចសហការរវាងអគ្គនាយកដ្ឋានពន្ធនាគារ និងទីភ្នាក់ងារជាតិមុខរបរ និងការងារ។ គោលបំណងនៃវិធីសាស្ត្រនេះគឺដើម្បីគាំទ្រដល់ការដាក់បញ្ចូលជនជាប់ឃុំទៅជាអ្នកទទួលផលពីកម្មវិធីរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ។ ភ្នាក់ងារមជ្ឈមណ្ឌលការងារនឹងរៀបចំការបណ្តុះបណ្តាលជំនាញផ្សេងៗ សម្រាប់ជនជាប់ឃុំមុនពេលដោះលែង ដើម្បីរៀបចំសមាហរណកម្មរបស់ពួកគេ។

បណ្ណាល័យ ២៨

ជនជាប់ឃុំចំនួន ៤២ ២៦៤ នាក់

អ្នកអាន ១០ ០០០ នាក់ក្នុងមួយខែ

ប្រព័ន្ធឧបករណ៍ឌីជីថល នៅក្នុងបណ្ណាល័យចំនួន ១៥

មានអ្នកទទួលផល ១៥ ៥០០នាក់

អ្នករៀន ថ្នាក់អក្ខរកម្ម ១ ០៦៩ នាក់

សិក្ខាសាលាសិល្បៈចំនួន ២



# កម្មវិធីអប់រំក្នុងពន្ធនាគារ

**អប់រំឌីជីថលដោយមិនភ្ជាប់បណ្តាញអ៊ីនធឺណិត ៖** ដើម្បីពង្រឹងការរៀនសូត្ររបស់ជនជាប់ឃុំ និងគាំទ្រពួកគេក្នុងការរៀបចំសមាហរណកម្មឡើងវិញ ស៊ីប៉ាបានសហការជាមួយអង្គការដៃគូ Passerelles numériques ដើម្បីបង្កើតកម្មវិធីអប់រំឌីជីថលដោយមិនភ្ជាប់បណ្តាញអ៊ីនធឺណិត។ គម្រោងនេះត្រូវបានបង្កើតក្នុងពន្ធនាគារចំនួន១៥ ដែលពន្ធនាគារនីមួយៗមានបំពាក់ដោយ NomadLab ដែលជាកម្មវិធីឧបករណ៍ឌីជីថលដោយមិនភ្ជាប់បណ្តាញអ៊ីនធឺណិត។ ពន្ធនាគារនីមួយៗទទួលបានកុំព្យូទ័រដប់គ្រឿង ជាមួយនឹងឯកសារអំណានប្រមាណ៨០០ច្បាប់ ឯកសារវីដេអូអប់រំចំនួន២៦០ និងកម្មវិធីឌីជីថលមិនភ្ជាប់បណ្តាញអ៊ីនធឺណិតចំនួន១២០ សម្រាប់ជនជាប់ឃុំ។ នៅឆ្នាំ២០២៣ ជនជាប់ឃុំជាង៤០០០នាក់ អាចចូលប្រើប្រាស់មាតិកាដែលបានបង្កើតឡើងនៅក្នុងមន្ទីរពិសោធន៍ឌីជីថលដោយមិនភ្ជាប់បណ្តាញអ៊ីនធឺណិតទាំងនេះ។ ក្រុមការងារអង្គការស៊ីប៉ាបានផ្តល់វគ្គបណ្តុះបណ្តាលចំនួន១០ ដល់មន្ត្រីពន្ធនាគារចំនួន៧៩នាក់ដែលទទួលបន្ទុក លើការប្រើប្រាស់ NomadLab។ នៅឆ្នាំ២០២៤ ពន្ធនាគារចំនួន១៣ផ្សេងទៀត ក៏នឹងទទួលបានកម្មវិធីឧបករណ៍ឌីជីថលដោយមិនភ្ជាប់បណ្តាញអ៊ីនធឺណិតផងដែរ។

**សកម្មភាពវប្បធម៌ និងច្នៃប្រឌិត ៖** សកម្មភាពសិល្បៈនៅក្នុងពន្ធនាគារ មានវិសាលភាពស្នាដៃច្នៃប្រឌិត រួមមានការតែងនិពន្ធ គំនូរខ្មៅដៃ និងគំនូរពណ៌។ ស៊ីប៉ាបានផ្តល់សិក្ខាសាលាសរសេរលើកដំបូង ដឹកនាំដោយអ្នកកាសែតស្ម័គ្រចិត្តខ្មែរ-ស្វីស ដែលធ្វើឡើងជាមួយជនជាប់ឃុំស្ត្រីចំនួនប្រាំពីរនាក់ នៅក្នុងពន្ធនាគារម២។ ក្រុមបោះពុម្ពស៊ីប៉ាបានជ្រើសរើសស្នាដៃចំនួនបីមកបោះពុម្ព និងចែកចាយដល់ពន្ធនាគារទាំងអស់។ នៅខែធ្នូ ឆ្នាំ២០២៣ ស៊ីប៉ាបានចាប់ដៃគូជាមួយ Clowns Sans Frontières (CSF) និងហ្វារពន្លឺសិល្បៈ ដើម្បីរៀបចំកម្មវិធីសិល្បៈមួយដែលរួមបញ្ចូលគ្នារវាងអាយ៉ង សៀក ល្ខោន និងតន្ត្រី។ ជនជាប់ឃុំស្ត្រីប្រមាណ២០នាក់ត្រូវបានជ្រើសរើស និងបណ្តុះបណ្តាលឱ្យចូលរួមក្នុងការសម្តែងនេះ។

**គម្រោងសាកល្បងប្រកបដោយភាពច្នៃប្រឌិតនៅក្នុងពន្ធនាគារចំនួនប្រាំពីរ ៖** ចាប់តាំងពីខែកក្កដា ឆ្នាំ២០២៣ និងសម្រាប់រយៈពេលពីរឆ្នាំ ស៊ីប៉ាទទួលបានការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុពី Fonds d'Innovation pour le Développement (FID) ដើម្បីសាកល្បងកម្មវិធីពហុព័ត៌មានប្រកបដោយភាពច្នៃប្រឌិត ( ឌីជីថល សោតទស្សន៍ ឯកសារ និងការបង្រៀន ) សម្រាប់ការអប់រំ និងសមាហរណកម្មសង្គម-វិជ្ជាជីវៈ។



*“NomadLab គឺជាឧបករណ៍ដ៏មានប្រយោជន៍សម្រាប់ជនជាប់ឃុំ។ ពួកគេអាចស្វែងរកកម្មវិធីជាច្រើន និងអភិវឌ្ឍជំនាញភាសា និងបំណិនជីវិត។ វាក៏ជួយកាត់បន្ថយភាពតានតឹង និងកង្វល់របស់ពួកគេផងដែរ។ តាមរយៈការប្រើប្រាស់ NomadLab ជនជាប់ឃុំជាច្រើនបានបង្កើតផ្នត់គំនិត អាកប្បកិរិយា និងទស្សនៈវិជ្ជមានបន្ថែមទៀតលើជីវិត។”*

**លោក ខៀវ វណ្ណារិទ្ធ**
បណ្ណារក្សនៃបណ្ណាល័យពន្ធនាគារខេត្តកំពត



គាំទ្រដល់សិស្សមធ្យមសិក្សានៅតំបន់ជនបទ និងសមាជិកនៃអង្គការសហគមន៍យុវជនមូលដ្ឋានដើម្បីចូលរួមចំណែកធ្វើឱ្យកាន់តែប្រសើរឡើងនូវលទ្ធភាពទទួលបានការងារ និងក្លាយជាតួអង្គក្នុងការរួមសាមគ្គីអភិវឌ្ឍសង្គម និងការអប់រំក្នុងសហគមន៍។

# កម្មវិធី អភិវឌ្ឍយុវជន


© Laurent Jannic

# អភិវឌ្ឍយុវជន

*បរិបទ ៖ កម្ពុជាមានយុវជនអាយុពី១៥ទៅ២៩ឆ្នាំ ប្រមាណ ២៦.៤% នៃប្រជាជនសរុប។ លទ្ធភាពទទួលបានការអប់រំប្រកបដោយគុណភាពនៅមានកម្រិតនៅឡើយនៅតំបន់ដាច់ស្រយាល ហើយអត្រាបោះបង់ការសិក្សាក៏មានកម្រិតខ្ពស់ចំពោះយុវជនដែលទើបចូលក្នុងទីផ្សារការងារ ដោយភាគច្រើនមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ ចាប់តាំងពីឆ្នាំ២០២១ ស៊ីប៉ាបានបង្កើតគម្រោងមួយ ដែលមានឈ្មោះថា «ការលើកស្ទួយលទ្ធភាពទទួលបានការងារ និងភាពជាពលរដ្ឋសកម្មរបស់យុវជន» ដោយទទួលបានការគាំទ្រពីទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ AFD និងអ្នកឧបត្ថម្ភផ្សេងទៀត។ ដោយមានការសហការជាមួយ ក្រសួងអប់រំ យុវជន និងកីឡា គម្រោងនេះមានគោលបំណងបង្កើនទស្សនវិស័យការងារ និងពង្រឹងការចូលរួមសាមគ្គីអភិវឌ្ឍសង្គមនៃយុវជន។*

## បណ្ណាល័យ និងជ្រុងតម្រង់ទិសវិជ្ជាជីវៈ

ស៊ីប៉ាបានបង្កើតបណ្ណាល័យ និងជ្រុងតម្រង់ទិសវិជ្ជាជីវៈចំនួន១៦ ដោយបំពាក់គ្រឿងសង្ហារិមបន្ថែម ព្រមទាំងឯកសារ និងកម្មវិធីឧបករណ៍ឌីជីថល (NomadLab) បង្កើតឡើងដោយអង្គការដៃគូ Passerelles numériques។ ឯកសារជាង៨០០ ច្បាប់ និងកុំព្យូទ័រចំនួនប្រាំបី (Chromebooks) ជាមួយនឹងកម្មវិធីជាង១១០ដោយភ្ជាប់ និងមិនភ្ជាប់អ៊ីនធឺណិត កំពុងផ្តល់ជូនសិស្សានុសិស្សជាង ២២ ០០០នាក់ នូវមធ្យោបាយបន្ថែមដើម្បីគាំទ្រដល់ការរៀនសូត្រ និងតម្រង់ទិសវិជ្ជាជីវៈ។

យើងបានបណ្តុះបណ្តាលបណ្ណារក្សទីប្រឹក្សាគណៈកម្មការគ្រប់គ្រងសាលា និងមន្ត្រីនៃក្រសួងអប់រំ យុវជន និងកីឡាដែលពាក់ព័ន្ធលើការគ្រប់គ្រង និងប្រើប្រាស់ធនធានពហុព័ត៌មាននៃបណ្ណាល័យមណ្ឌលតម្រង់ទិសវិជ្ជាជីវៈ។ លើសពីនេះ យើងបានរៀបចំវគ្គពិភាក្សាជំនាញ ដោយមានអ្នកចូលរួមជាង ៦០នាក់ ដើម្បីលើកកម្ពស់ការប្រើប្រាស់បណ្ណាល័យ និងការណែនាំសិស្ស។

## វេទិកាការងារ

ស៊ីប៉ាសហការជាមួយគណៈគ្រប់គ្រងវិទ្យាល័យនីមួយៗ រៀបចំវេទិកាការងារចំនួន៣០ដង រួមមានវេទិកាការងារតាមប្រព័ន្ធអ៊ីនធឺណិតចំនួន១៥ ដើម្បីណែនាំសិស្សអំពីឱកាសសិក្សា និងវិជ្ជាជីវៈ ព្រមទាំងវិធីសាស្ត្រល្អបំផុតដើម្បីរៀបចំអនាគតរបស់ពួកគេបន្ទាប់ពីបញ្ចប់ការសិក្សា។

ព្រឹត្តិការណ៍ទាំងនេះបានប្រមូលផ្តុំអ្នកតាំងពិព័រណ៍គ្រប់វិស័យរួមទាំងគ្រឹះស្ថានឧត្តមសិក្សា សាលាបច្ចេកទេសរដ្ឋ ឯកជន និងក្រុមហ៊ុន។ សិស្សបានជួបគ្រឹះស្ថានសិក្សា និងក្រុមហ៊ុនឯកជនទាំងនេះ ដើម្បីស្វែងយល់កាន់តែច្បាស់អំពីទីផ្សារការងារ និងការជ្រើសរើសមុខវិជ្ជាសិក្សានាពេលអនាគត។



*“ដោយមានជំនួយពីគម្រោងស៊ីប៉ា បណ្ណាល័យរបស់យើងមានសៀវភៅជាច្រើនប្រភេទ ដែលសិស្សអាចខ្ចីយកទៅអាននៅផ្ទះ ឬពេលសម្រាកលំហែកាយ ដើម្បីជួយអភិវឌ្ឍចំណេះដឹងរបស់ពួកគេ។ លើសពីនេះ សិស្សានុសិស្សរីករាយពេលកំពុងរៀន ដោយសារល្បែងសិក្សានានាដែលមាននៅលើ NomadLab ។”*

**អ្នកស្រី ឡុង លាភសុជាតា**
បណ្ណារក្សនៃវិទ្យាល័យព្រះសីហនុ ខេត្តកំពង់ចាម

**បណ្ណាល័យមណ្ឌល តម្រង់ទិសវិជ្ជាជីវៈចំនួន១៦ បំពាក់ដោយ NomadLab**

**សិស្សទទួលផលចំនួន ២២ ០០០ នាក់**

**វេទិកាការងារចំនួន ៣០**

**បណ្តុះបណ្តាលគ្រូបង្រៀនចំនួន ៦២ នាក់ (ស្ត្រី ១៩ នាក់)**




# អភិវឌ្ឍយុវជន

## ភាពជាពលរដ្ឋសកម្មរបស់យុវជនដើម្បីអភិវឌ្ឍសហគមន៍

គម្រោងនេះក៏គាំទ្រសកម្មភាពរបស់អង្គការសហគមន៍យុវជនមូលដ្ឋានចំនួន១៨ ដើម្បីរួមចំណែកអភិវឌ្ឍការអប់រំសង្គមរបស់សហគមន៍។ អង្គការសហគមន៍យុវជនមូលដ្ឋានទាំងនេះគឺជា អង្គការសង្គមស៊ីវិលដែលមានមូលដ្ឋាននៅតាមឃុំ ដើម្បីអនុវត្តសកម្មភាពអប់រំសង្គម។ សមាជិកនៃអង្គការសហគមន៍យុវជនមូលដ្ឋានជាយុវជន ដែលមានអាយុពី១២ ដល់ ១៨ឆ្នាំ ហើយពួកគេរួមគ្នាអនុវត្តសកម្មភាពស្ម័គ្រចិត្តក្នុងគោលបំណងអភិវឌ្ឍការអប់រំ និងលើកកម្ពស់ការអាន ៖

- សមាជិកគ្រូតូចចំនួន១០៥នាក់ រៀបចំវគ្គបំប៉នភាសាខ្មែរ និងគណិតវិទ្យា ពី៤ទៅ៥ដងក្នុង១សប្ដាហ៍ ដោយស្របនឹងកម្មវិធីអប់រំថ្នាក់ជាតិដល់កុមារដែលជាសិស្សបឋមសិក្សាចំនួន ៩៥០នាក់។
- សមាជិកនៃអង្គការសហគមន៍យុវជនមូលដ្ឋានចំនួន៨៣នាក់ ផ្ដល់ការខ្ចីសៀវភៅក្នុងសហគមន៍ តាមរយៈបណ្ណាល័យសាក់កាដូ ដល់អ្នកភូមិប្រមាណ៣៥០នាក់ក្នុងមួយខែ។
- បណ្ណាល័យខ្នាតតូចចំនួន២១ ដែលមាននៅតាមផ្ទះសមាជិកនៃអង្គការសហគមន៍យុវជនមូលដ្ឋាន ស្វាគមន៍កុមារជាង៣៥០នាក់ជារៀងរាល់ខែ។
- យុទ្ធនាការអប់រំចំនួន២៧ ត្រូវបានរៀបចំក្នុងឆ្នាំ២០២៣ ដោយមានអ្នកចូលរួមសរុបចំនួន១៧០០នាក់ ជុំវិញប្រធានបទដូចជា សុវត្ថិភាពចរាចរណ៍ បរិស្ថាន ការលើកកម្ពស់ការអាន និងការចុះឈ្មោះចូលរៀន។

## ការផលិតសម្ភារៈអប់រំ

ជាផ្នែកមួយនៃគម្រោង ស៊ីប៉ាបានផលិតឯកសារអប់រំបោះពុម្ព និងឌីជីថល ដើម្បីផ្ដល់ជូនយុវជននូវឯកសារបន្ថែមអំពី ៖ ការណែនាំអំពីអាជីព និងអភិវឌ្ឍខ្លួន ព្រមទាំងកម្មវិធីអប់រំឌីជីថល។ ចាប់តាំងពីឆ្នាំ២០២១ សម្ភារៈជាច្រើនត្រូវបានផលិត និងចែកចាយនៅក្នុងវិទ្យាល័យគោលដៅ ៖

- ឯកសារអំពីការអភិវឌ្ឍខ្លួនចំនួនបី ៖ ផ្ទាំងរូបភាព ដែលមានចំណងជើងថា «ផ្លូវមួយដើម្បីរៀបចំអនាគតរបស់ខ្ញុំ» សៀវភៅដែលមានចំណងជើងថា «ចេះរៀន ៖ ១១គន្លឹះដើម្បីក្លាយជាសិស្សជោគជ័យ» និងសៀវភៅមគ្គុទេសក៍សម្រាប់យុវវ័យ «ការងារស្ម័គ្រចិត្តសម្រាប់សមាជិកអង្គការមូលដ្ឋាន» ត្រូវបានបង្កើតឡើងដើម្បីលើកទឹកចិត្តយុវជនក្នុងការចូលរួមក្នុងសកម្មភាពដើម្បីសហគមន៍។
- សៀវភៅតម្រង់ទិសវិជ្ជាជីវៈចំនួនប្រាំចំណងជើង ៖ ទស្សនាវដ្ដីអាជីព «តើអ្នកត្រៀមខ្លួនហើយឬនៅ?» ចំនួនបីចំណង ស្ដីពីអាជីពក្នុងវិស័យថាមពលកកើតឡើងវិញ កសិកម្ម និងទេសចរណ៍ និងសៀវភៅតម្រង់ទិសវិជ្ជាជីវៈចំនួនពីរ (តម្រង់ទិសវិជ្ជាជីវៈអំពីអាជីពក្នុងវិស័យហោះហើរ និងអាជីពក្នុងបច្ចេកវិទ្យាព័ត៌មាន)។
- វីដេអូអប់រំចំនួនបួនត្រូវបានបង្កើតឡើង និងបានដាក់បញ្ចូលទៅក្នុង NomadLab ៖ ការរៀន ការយល់ដឹងដោយខ្លួនឯង ការរៀបចំការងារ និងការគ្រប់គ្រងលុយ។






គាំទ្រការអប់រំរបស់ប្រជាជនកម្ពុជា តាមរយៈការបោះពុម្ពផ្សាយ និងការផ្តល់សៀវភៅប្រកបដោយគុណភាពខ្ពស់ស្របតាមតម្រូវការ និងចំណង់ចំណូលចិត្តរបស់អ្នកអានដែលជាកុមារ គ្រូបង្រៀន អ្នកអប់រំ និងសាធារណជនទូទៅ។

# កម្មវិធី បោះពុម្ពផ្សាយ



# កម្មវិធីបោះពុម្ពផ្សាយ

*បរិបទ ៖ បច្ចុប្បន្ន ចំណាប់អារម្មណ៍ក្នុងការអានសៀវភៅនៅតាមសាលារៀន និងតាមផ្ទះមានការកើនឡើងគួរឱ្យកត់សម្គាល់។ ការកើនឡើងនេះអាចសម្គាល់បានដោយមើលឃើញជោគជ័យនៃពិព័រណ៍សៀវភៅកម្ពុជា ដែលបានរៀបចំធ្វើឡើងតាំងពីឆ្នាំ២០១០ ហើយនៅតែបន្តទាក់ទាញអ្នកចូលរួមដែលជាអ្នកអានជារៀងរាល់ឆ្នាំ។ ទោះបីជាយ៉ាងណាក៏ដោយ វិស័យបោះពុម្ពនៅកម្ពុជា នៅតែមិនទាន់មានភាពរឹងមាំនៅឡើយទេ ចំណែកឯអាជីពដែលទាក់ទងទៅនឹងវិស័យបោះពុម្ពផ្សាយក៏មិនសូវទទួលបានការយកចិត្តទុកដាក់គ្រប់គ្រាន់ក្នុងសង្គមកម្ពុជាដែរ។*

តាំងពីឆ្នាំ២០០១មក អង្គការស៊ីប៉ាបានចាប់ផ្តើមបោះពុម្ពផ្សាយសៀវភៅអប់រំ និងសៀវភៅអក្សរសិល្ប៍ជាភាសាខ្មែរ។ សៀវភៅមួយចំនួនធំត្រូវបានចែកចាយដោយឥតគិតថ្លៃ សម្រាប់កម្មវិធីផ្សេងៗដែលគាំទ្រដោយអង្គការស៊ីប៉ា និងអង្គការដទៃទៀត ចំណែកសៀវភៅមួយចំនួនទៀតអាចរកបាននៅបណ្ណាគារនានា។ នៅឆ្នាំ២០២៣ ក្រុមការងារបោះពុម្ពផ្សាយរបស់យើងបានបោះពុម្ពសៀវភៅថ្មីចំនួន១៩ចំណងជើង និងបោះពុម្ពឡើងវិញ ៥០ចំណងជើង ដែលសរុបទាំងអស់គឺបោះពុម្ពបាន៣,៣លានក្បាល ចាប់តាំងពីឆ្នាំ២០០១មក។

នៅឆ្នាំ២០២៣ក្រុមការងារបោះពុម្ពផ្សាយរបស់យើងបានបកប្រែពីភាសាបារាំងរឿងឆាករូបភាពសម្រាប់យុវវ័យដែលមានចំណងជើងថា «ដំណើរផ្សងព្រេងរបស់ស្តេចស្វា» និងដើម្បីលើកកម្ពស់ការអានបែបកម្សាន្ត។ យើងក៏បានបោះពុម្ពផ្សាយនូវចំណងជើងជាច្រើនសម្រាប់សិស្សានុសិស្សកម្រិតមធ្យម និងវិទ្យាល័យ ដើម្បីលើកកម្ពស់ការតម្រង់ទិសវិជ្ជាជីវៈ និងអភិវឌ្ឍខ្លួន។ ក្រុមសៀវភៅថ្មីមួយដែលមានឈ្មោះថា មគ្គុទេសក៍សម្រាប់យុវជន ត្រូវបានដាក់ឱ្យដំណើរការដើម្បីគាំទ្រដល់យុវជនក្នុងការអភិវឌ្ឍខ្លួនរបស់ពួកគេ។

អង្គការស៊ីប៉ានៅបន្តគាំទ្រដល់ការអភិវឌ្ឍជំនាញធនធានមនុស្សក្នុងវិស័យបោះពុម្ពផ្សាយ។ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២៣ ស៊ីប៉ាបានសហការជាមួយវិទ្យាស្ថានបារាំងនៃកម្ពុជា ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលសិក្ខាកាមចំនួន១៥នាក់ ស្តីពីការនិពន្ធ និងគំនូរ។ គ្រូបង្វឹកជនជាតិបារាំងពីរនាក់បានបណ្តុះបណ្តាលសិក្ខាកាមនៅក្នុងការនិពន្ធនិងគូររឿងរបស់ពួកគេ។ រឿងដែលសហការនិពន្ធដោយបុគ្គលិកស៊ីប៉ាពីរនាក់ ត្រូវបានជ្រើសរើស ហើយនឹងត្រូវបោះពុម្ពនៅឆ្នាំ២០២៤។

ជាផ្នែកមួយនៃបេសកកម្មចម្បងរបស់ខ្លួនក្នុងការអភិវឌ្ឍការអាន ស៊ីប៉ាតែងតែចូលរួមនៅក្នុងព្រឹត្តិការណ៍ផ្សេងៗដែលទាក់ទងនឹងការលើកកម្ពស់សៀវភៅ និងការអាន ដូចជាពិព័រណ៍ សន្និសីទ សិក្ខាសាលាជាដើម។ ជារៀងរាល់ឆ្នាំ ស៊ីប៉ាបានចូលរួមយ៉ាងសកម្មក្នុងការរៀបចំពិព័រណ៍សៀវភៅកម្ពុជា ដើម្បីលើកកម្ពស់ការអានដល់សាធារណជនទូទៅ។

> *ដោយមានការណែនាំពីក្រុមការងារស៊ីប៉ា ខ្ញុំទទួលបានការយល់ដឹងថ្មីៗអំពីកុមារ ការចូលចិត្ត និងការមិនចូលចិត្តរបស់ពួកគេ បុគ្គលិកលក្ខណៈ អាកប្បកិរិយារបស់ពួកគេ និងប្រភេទសៀវភៅដែលពួកគេចូលចិត្តអាន។ ការនិពន្ធសៀវភៅ សុភីធ្វើម្ហូប អនុញ្ញាតឱ្យខ្ញុំយល់យ៉ាងច្បាស់ថាសៀវភៅរបស់កុមារគឺជាអ្វី។ បើមានឱកាស ខ្ញុំចង់បោះពុម្ពសៀវភៅកុមារផ្សេងទៀតជាមួយអង្គការស៊ីប៉ា។*



លោក រ៉េត សុភ័ក្រ
អ្នកនិពន្ធសៀវភៅ សុភីធ្វើម្ហូប

សៀវភៅ ១៩ ចំណងជើងថ្មីបានបោះពុម្ព

សៀវភៅ២៨៩ចំណងជើង និង២១ក្រុម តាំងពីឆ្នាំ២០០១មក

សៀវភៅ៣,៣លានក្បាល ត្រូវបានបោះពុម្ព ចាប់ពីឆ្នាំ ២០០១

វគ្គបណ្តុះបណ្តាល ៨៥ ត្រូវបានរៀបចំឡើង តាំងពីឆ្នាំ២០០៤



# កម្មវិធីបោះពុម្ពផ្សាយ

### ការវិវត្តនៃកម្មវិធីបោះពុម្ពទៅជា «សហគ្រាសសង្គម»

នៅឆ្នាំ២០២៣ ស៊ីប៉ាបានប្រែក្លាយកម្មវិធីបោះពុម្ពផ្សាយទៅជា «សហគ្រាសសង្គម»។ ការអភិវឌ្ឍនេះគោរពតាមបទប្បញ្ញត្តិរបស់កម្ពុជា ដែលកំណត់ដល់អង្គការក្រៅរដ្ឋាភិបាលចុះបញ្ជីសហគ្រាសដែលអនុវត្តសកម្មភាពពាណិជ្ជកម្ម ហើយក៏ជាផ្នែកមួយក្នុងការសម្រេចគោលដៅរបស់ស៊ីប៉ាដើម្បីអភិវឌ្ឍឧស្សាហកម្មសៀវភៅជាតិផងដែរ។ គោលបំណងគឺដើម្បីលើកកម្ពស់ការអានដល់អ្នកអានឱ្យបានច្រើន ហើយនៅតែរក្សាបាននូវបេសកកម្មជាមូលដ្ឋានរបស់យើងក្នុងការអប់រំកុមារ និងយុវជន។ កម្មវិធី និងការផ្សព្វផ្សាយសៀវភៅរបស់ស៊ីប៉ាមានគោលបំណងតែមួយ គឺដើម្បីលើកកម្ពស់ការអានតាមរយៈយុទ្ធសាស្ត្រដែលមានគិតគូរច្បាស់លាស់ លើប្រធានបទសមស្រប និងអ្នកអានគោលដៅ។

## សៀវភៅថ្មីសំខាន់ៗដែលបានបោះពុម្ពនៅឆ្នាំ២០២៣



*សៀវភៅសម្រាប់ការអភិវឌ្ឍយុវជន ៖*

**ចេះរៀន - ១១គន្លឹះដើម្បីក្លាយជាសិស្សជោគជ័យ**
**តម្រង់ទិសវិជ្ជាជីវៈ អាជីពក្នុងវិស័យហោះហើរនិង**
**តម្រង់ទិសវិជ្ជាជីវៈ អាជីពក្នុងបច្ចេកវិទ្យាព័ត៌មាន**

ដើម្បីគាំទ្រការអប់រំរបស់យុវជន និងដំណើរការជ្រើសរើសអាជីព/ការងាររបស់ពួកគេ។



**អូនកាទៅសាលា**

គូររូបដោយ លោកស្រី ម៉ាន់ ម៉ាឡែន ដែលជាជ័យលាភីលេខ១ក្នុងកម្មវិធីប្រកួតអ្នកគំនូរសៀវភៅកុមារ ដែលរៀបចំដោយអង្គការស៊ីប៉ា។



**ការប្រែប្រួលអាកាសធាតុ**

បកប្រែពីភាសាបារាំង សៀវភៅនេះបង្កើនការយល់ដឹងក្នុងចំណោមអ្នកអានកម្ពុជាវ័យក្មេង អំពីមូលហេតុ និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។



**សត្វល្អិត**

ការបង្ហាញអំពីប្រភេទសត្វល្អិតផ្សេងៗ និងតួនាទីរបស់វានៅក្នុងប្រព័ន្ធអេកូឡូស៊ីរបស់យើង រចនា និងបោះពុម្ពជាភាសាខ្មែរ បារាំង និងអង់គ្លេស ក្នុងភាពជាដៃគូជាមួយវិទ្យាស្ថានប៉ាស្ទ័រ។

### មតិពីអតិថិជនរបស់ស៊ីប៉ា

ញ៉ាន ផល្លីសុភេន ៖ *«សៀវភៅគ្រួសារខ្ញុំ ៨០% មកពីស៊ីប៉ា»*

ណាភា សុខជឹម ៖ *«ខ្ញុំមានសៀវភៅគ្រប់ចំណងជើង ព្រោះខ្ញុំចូលចិត្តអានសៀវភៅដែលបោះពុម្ពដោយស៊ីប៉ា។»*

# ព្រឹត្តិការណ៍សំខាន់ៗ



ខែមករា

## ការចែកចាយសម្ភារៈសិក្សាដល់កុមារនៅតាមឡានដ្ឋ

ដើម្បីជំរុញដល់ការចុះឈ្មោះចូលរៀនសម្រាប់ឆ្នាំសិក្សាថ្មី ក្រុមការងារអង្គការស៊ីប៉ា បានចែកសម្ភារៈសិក្សាដល់កុមារជាង ៣០០នាក់ ដែលរស់នៅក្នុងតំបន់ឡានដ្ឋចំនួន១២ ក្នុងខេត្តកណ្ដាល។ ក្រុមការងាររបស់យើងក៏បានសម្របសម្រួលជាមួយនាយកសាលា ដើម្បីជួយសម្រួលដល់ការចុះឈ្មោះអ្នកទទួលផលពីស៊ីប៉ា។



ខែកុម្ភៈ

## ការចែកចាយសៀវភៅទៅកាន់បណ្ណាល័យសាលារៀន

អង្គការស៊ីប៉ាបានចែកសៀវភៅថ្មីដល់សាលាបឋមសិក្សាចំនួន៣៥ ក្នុងខេត្តកំពត និងរាជធានីភ្នំពេញ។ សាលានីមួយៗបានទទួលសៀវភៅថ្មីៗ ដើម្បីលើកកម្ពស់ការអានក្នុងចំណោមសិស្ស។ សិស្សានុសិស្សនីមួយៗក៏បានចូលរួមក្នុងវគ្គយល់ដឹងពីបរិស្ថានដែលរៀបចំដោយបណ្ណារក្សស៊ីប៉ា។



ខែមីនា

## យុទ្ធនាការអានដែលរៀបចំដោយសមាជិកនៃអង្គការសហគមន៍យុវជនមូលដ្ឋានពាមមន្ទារ

ដោយសហការជាមួយសាលាបឋមសិក្សាក្រចាប់ អង្គការស៊ីប៉ាបានគាំទ្រសមាជិកនៃអង្គការសហគមន៍យុវជនមូលដ្ឋានពាមមន្ទារក្នុងការរៀបចំយុទ្ធនាការអំណាន ដើម្បីលើកទឹកចិត្តយុវជនក្នុងសហគមន៍ឱ្យចេះអាន និងអបអរសាទរទិវាជាតិអំណាននៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៣។




ខែមីនា

## ការចូលរួមក្នុងសិក្ខាសាលាស្ដីពីការអប់រំនៅក្នុងពន្ធនាគារនៅទីក្រុងម៉ានីលនៃប្រទេសហ្វីលីពីន

សិក្ខាសាលាមួយដែលមានចំណងជើងថា «អានផ្លូវរបស់អ្នក ៖ ដើម្បីកំណែទម្រង់ពន្ធនាគារតាមរយៈបណ្ណាល័យសម្រាប់ការអប់រំជនជាប់ឃុំ» ដែលរៀបចំដោយ UNODC (ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម) ត្រូវបានប្រារព្ធឡើងនៅទីក្រុងម៉ានីល ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣។ លោកស្រី Béatrice Montariol បានទទួលការអញ្ជើញក្នុងនាមជាវាគ្មិនតំណាងអង្គការស៊ីប៉ា អមដោយនាយកប្រតិបត្តិនៃអគ្គនាយកដ្ឋានពន្ធនាគារ និងនាយកប្រតិបត្តិមកពីអង្គការ UNODC កម្ពុជា។




ខែមេសា

## ការបោះពុម្ពផ្សាយ សៀវភៅ «ស៊ីនួន» ជាភាសាខ្មែរ

ជាង៥០ឆ្នាំបន្ទាប់ពីការបោះពុម្ពលើកដំបូងនៃសៀវភៅ «ស៊ីនួន» ជាភាសាបារាំង ដែលនិពន្ធដោយលោកស្រី Odile Wertheimer អង្គការស៊ីប៉ាមានកិត្តិយសបកប្រែ និងបោះពុម្ពសៀវភៅនេះជាភាសាខ្មែរជាលើកដំបូង។ អ្វីដែលនឹកស្មានមិនដល់នោះ ក្រុមការងារស៊ីប៉ាបានរកឃើញស៊ីនួនពិតប្រាកដភ្លាមៗក្រោយការបោះពុម្ពផ្សាយនេះ គឺលោកស្រី ផូ ស៊ីនួន ដែលសព្វថ្ងៃមានអាយុប្រហែល ៦០ឆ្នាំហើយ។



ខែមិថុនា

## បង្កើតកម្រងសៀវភៅថ្មី «មគ្គទេសក៏សម្រាប់យុវវ័យ»

ដើម្បីផ្ដល់ធនធានសម្រាប់យុវជនក្នុងការស្វែងយល់ និងអភិវឌ្ឍខ្លួនឯង ស៊ីប៉ាបានបង្កើតកម្រងសៀវភៅថ្មីមួយដែលមានឈ្មោះថា «មគ្គទេសក៏សម្រាប់យុវវ័យ» ដែលផ្ដោតលើប្រធានបទសំខាន់ៗជាច្រើនជុំវិញការរៀនសូត្រ ការអភិវឌ្ឍខ្លួន និងតម្រង់ទិសវិជ្ជាជីវៈ។



ខែកក្កដា

## ខួប១០ឆ្នាំនៃភាពជាដៃគូជាមួយ RESPEK

ខែកក្កដា ឆ្នាំ២០២៣ គឺជាខួបលើកទី១០ នៃភាពជាដៃគូរវាងស៊ីប៉ា និង RESPEK ក្នុងការអនុវត្តកម្មវិធីបណ្ណាល័យចល័តក្នុងខេត្តរតនគិរី។ គោលបំណងនៃកិច្ចសហការនេះគឺដើម្បីកាត់បន្ថយអនក្ខរភាព ផ្តល់លទ្ធភាពទទួលបានសៀវភៅដល់កុមារ និងយុវជនក្នុងខេត្តរតនគិរី និងពង្រឹងការអប់រំរបស់ពួកគេ។



ខែសីហា

## ការចាប់ផ្តើមនៃគម្រោងសាកល្បងថ្មី ដែលជាផ្នែកមួយនៃកម្មវិធី «ការអប់រំក្នុងពន្ធនាគារ»

អង្គការស៊ីប៉ាបានចាប់ផ្តើមការអភិវឌ្ឍសាកល្បង នៃមជ្ឈមណ្ឌលពហុព័ត៌មាននៅក្នុងពន្ធនាគារចំនួនប្រាំពីរ ដែលគាំទ្រដោយមូលនិធិ FID ដើម្បីលើកកម្ពស់សមាហរណកម្មសង្គម-វិជ្ជាជីវៈរបស់ជនជាប់ឃុំឱ្យកាន់តែប្រសើរឡើង។ តាមរយៈការផ្តល់ឧបករណ៍ និងឱកាសសមរម្យដល់ពួកគេ យើងមានទំនុកចិត្តលើសក្តានុពលរបស់ពួកគេ ក្នុងការកសាងជីវិតរបស់ពួកគេឡើងវិញ និងរួមចំណែកដ៏មានអត្ថន័យដល់សង្គមរបស់យើង។



ខែតុលា

## កិច្ចប្រជុំសម្របសម្រួលជាមួយស្រុកមុខកំពូល ដែលជាទីតាំងគម្រោងអប់រំតាមឡតដ្ឋ

ស៊ីប៉ាបានជួបអ្នកពាក់ព័ន្ធក្នុងគម្រោងឡតដ្ឋ ដើម្បីបង្ហាញដល់ពួកគេនូវគម្រោងថ្មីមួយដែលប្រព្រឹត្តទៅក្នុងរយៈពេលបីឆ្នាំ ( ចាប់ពីខែតុលា ឆ្នាំ២០២៣ ដល់ខែកញ្ញា ឆ្នាំ២០២៦ )។ គម្រោងនេះមានគោលបំណងផ្តល់ការអប់រំដល់កម្មករ និងកុមារដែលរស់នៅក្នុងតំបន់ឡតដ្ឋចំនួន៣២ ក្នុងស្រុកមុខកំពូល សរុប ១២០០ គ្រួសារ។



ខែវិច្ឆិកា

## យុទ្ធនាការចុះឈ្មោះឆ្នាំសិក្សាថ្មី

អង្គការសហគមន៍យុវជនមូលដ្ឋានចំនួន១០ មកពីខេត្តចំនួន៣ បានរៀបចំយុទ្ធនាការផ្សព្វផ្សាយការយល់ដឹងនៅក្នុងភូមិរបស់ពួកគេ ដើម្បីលើកកម្ពស់ការអប់រំ និងលើកទឹកចិត្តឪពុកម្តាយឱ្យចុះឈ្មោះកូនខ្លួនចូលរៀនសម្រាប់ឆ្នាំសិក្សាថ្មី។ យុទ្ធនាការទ្រង់ទ្រាយធំនេះបានទាក់ទាញអនាគតសិស្សានុសិស្ស ជាង ៦០០ នាក់។



ខែធ្នូ

## សហការរៀបចំពិព័រណ៍សៀវភៅថ្នាក់ជាតិលើកទី១០ នៃប្រទេសកម្ពុជា

ដោយបានដើរតួនាទីឈានមុខគេក្នុងការរៀបចំពិព័រណ៍សៀវភៅកម្ពុជា ចាប់តាំងពីការបង្កើតឡើងក្នុងឆ្នាំ២០១១ មក ក្រុមការងារ ស៊ីប៉ា មានមោទនភាពដែលបានចូលរួមក្នុងការត្រឡប់មកវិញនៃព្រឹត្តិការណ៍ពិព័រណ៍សៀវភៅឆ្នាំ ២០២៣ នេះ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីឧស្សាហកម្មបោះពុម្ពនៅកម្ពុជា និងលើកកម្ពស់ការអានដល់ប្រជាជនកម្ពុជា។ ឆ្នាំនេះ កម្មវិធីពិព័រណ៍សៀវភៅបានស្វាគមន៍អ្នកចូលរួមជាង២០ម៉ឺននាក់។



ខែធ្នូ

## គម្រោងសិល្បៈជាមួយអ្នកជាប់ឃុំក្នុងពន្ធនាគារម២

ដើម្បីលើកកម្ពស់សិល្បៈ និងភាពច្នៃប្រឌិតក្នុងចំណោមទណ្ឌិត ស៊ីប៉ាបានរៀបចំសិក្ខាសាលានិពន្ធដែលដឹកនាំដោយអ្នកសារព័ត៌មានស្ម័គ្រចិត្តខ្មែរ-ស្វីស ក៏ដូចជាការសម្តែងសិល្បៈដោយសហការជាមួយ Clowns Sans Frontières (CSF) និងហ្វារពន្លឺសិល្បៈ ដល់ទណ្ឌិតស្ត្រីនៅពន្ធនាគារម២។

# សកម្មភាពអប់រំផ្សេងៗ ក្រៅពីសៀវភៅ

ក្នុងនាមជាអ្នកជំនាញគរុកោសល្យ ដែលធ្វើការជាមួយជនងាយរងគ្រោះ អង្គការស៊ីប៉ាបានបង្កើតប្រធានបទអប់រំជាច្រើន ក្រោមការសហការជាមួយក្រុមហ៊ុន និងស្ថាប័នសំខាន់ៗមួយចំនួន។ ដោយសហការជាមួយស្ថាប័ន ក្រុមហ៊ុន និងសមាគមក្នុងស្រុក អង្គការស៊ីប៉ាធ្វើសកម្មភាពអប់រំទាំងនេះនៅតាមសហគមន៍ដាច់ស្រយាលតាមរយៈបណ្ណាល័យចល័ត ឬអង្គការសហគមន៍យុវជនមូលដ្ឋាន ឬក្លឹបយុវជន។ ក្នុងប្រធានបទនីមួយៗ អង្គការស៊ីប៉ា បង្កើតល្បែងអប់រំ និងសម្ភារៈបោះពុម្ព ព្រមទាំងសម្រួលសារទៅតាមវ័យរបស់កុមារ និងមនុស្សពេញវ័យ។

គោលបំណងរបស់សកម្មភាពទាំងនេះ គឺដើម្បីផ្លាស់ប្តូរទម្លាប់ និងលើកទឹកចិត្តអ្នកចូលរួមឱ្យផ្សព្វផ្សាយបន្តក្នុងគ្រួសារ និងសហគមន៍របស់ពួកគេ។

## ស្វែងយល់ពីប្រធានបទអប់រំរបស់យើង ៖

### សុខភាព និងអនាម័យ

ដើម្បីអភិវឌ្ឍ និងអនុវត្តគំនិតផ្តួចផ្តើមថ្មីដែលផ្សព្វផ្សាយសារសំខាន់ៗស្តីពីសុខភាព អនាម័យ និង អាហារូបត្ថម្ភទៅដល់ប្រជាជន ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន។

**ប្រធានបទ ៖**

- ការសម្អាតដៃ
- ការដុសធ្មេញ
- អនាម័យក្នុងការបរិភោគ
- ការបរិភោគទឹកស្អាត
- ការប្រើប្រាស់បង្គន់ត្រឹមត្រូវ
- សារៈសំខាន់នៃការបរិភោគក្រុមអាហារ៣ប្រភេទ វិតាមីនផ្សេងៗ និងរ៉ែ
- ការបំបៅដោះម្តាយ
- ទម្លាប់អនាម័យទប់ស្កាត់ជំងឺឆ្លងកូវីដ១៩



*វគ្គយល់ដឹងដែលផ្តល់ដោយបណ្ណាល័យចល័តស៊ីប៉ា បំពេញតម្រូវការសហគមន៍អណ្តែតទឹករបស់យើង ជាពិសេសវគ្គស្តីពីសុខភាព និងផែនការគ្រួសារ។ គ្រួសាររបស់ខ្ញុំ និងសមាជិកដទៃទៀតនៃសហគមន៍ ឥឡូវ មានរបៀបរស់នៅស្អាតជាងមុន ហើយយើងយល់ពីសារៈសំខាន់នៃការពន្យារកំណើត ដើម្បីបង្កើនគុណភាពជីវិតរបស់យើង។*

**លោក ប៊ុន ម៉ារ**
អាយុ ៤១ឆ្នាំ អ្នកចូលរួមវគ្គយល់ដឹងពីអង្គការស៊ីប៉ា

### សុវត្ថិភាពចរាចរណ៍

ដើម្បីចូលរួមចំណែកសកម្មភាពអប់រំស្តីពីច្បាប់ចរាចរណ៍ តាមរយៈវីដេអូ ខិត្តប័ណ្ណ សំណួរចម្លើយ និងល្បែងអប់រំផ្សេងៗ

**ប្រធានបទ ៖**

- ច្បាប់ចរាចរណ៍
- សីលធម៌ក្នុងការបើកបរ
- ការពាក់មួកសុវត្ថិភាព
- ការបើកបរលើសល្បឿនកំណត់
- ការប្រើប្រាស់ទូរស័ព្ទក្នុងពេលបើកបរ
- ការបើកបរក្នុងពេលស្រវឹង
- ការពិនិត្យភ្នែកសម្រាប់សុវត្ថិភាពបើកបរ



*ខ្ញុំទៅសាលារៀនជារៀងរាល់ថ្ងៃដោយជិះកង់ ដូច្នេះវាពិតជាសំខាន់សម្រាប់ខ្ញុំក្នុងការយល់ដឹងអំពីសុវត្ថិភាពចរាចរណ៍។ ខ្ញុំសូមថ្លែងអំណរគុណដល់បណ្ណារក្សដែលបានបង្រៀនខ្ញុំ និងកុមារដទៃទៀតអំពីអ្វីដែលត្រូវធ្វើ ដើម្បីធ្វើដំណើរប្រកបដោយសុវត្ថិភាពនៅលើដងផ្លូវ គោរពស្លាកសញ្ញាផ្លូវ និងយកចិត្តទុកដាក់ចំពោះយានជំនិះផ្សេងៗ។*

**សៀក គន្ធា**
អាយុ១២ឆ្នាំ សិស្សថ្នាក់ទី៦

## បរិស្ថាន

ដើម្បីអប់រំកុមារ និងយុវវ័យក្នុងការអភិវឌ្ឍទម្លាប់ល្អក្នុងការថែរក្សាបរិស្ថាន នៅតាមភូមិស្រុក តាមរយៈសកម្មភាពអប់រំផ្សេងៗ។

**សកម្មភាព ៖**

- វីដេអូអប់រំ និងសំណួរចម្លើយអំពីការប្រើប្រាស់ប្លាស្ទិក
- សិក្ខាសាលាអំពីស្លាកសញ្ញាហាមឃាត់
- ការអានសៀវភៅទាក់ទងនឹងបរិស្ថាន
- ការកែច្នៃសំរាមឡើងវិញ និងការណែនាំរបៀបប្រើប្រាស់ឡើងវិញ
- ការប្រមូលសំរាមតាមប្រភេទ
- ការប្រឡងប្រណាំង «ភូមិស្អាតជាងគេ»

## កម្មវិធីស្ទីម (STEAM) (វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និងគណិតវិទ្យា)

ដើម្បីជួយឱ្យកុមារស្វែងយល់ពីកម្មវិធីស្ទីម តាមរយៈសកម្មភាពអប់រំផ្សេងៗ ក្នុងគោលបំណងបំផុសការស្រឡាញ់ និងកំណត់អាជីពក្នុងវិស័យនេះ ដែលជាវិស័យមួយកំពុងតែមានតម្រូវការនៅកម្ពុជា។

**ប្រធានបទ ៖**

- **ជីវៈវិទ្យា** (សារពាង្គកាយមនុស្ស សត្វ និងរុក្ខជាតិ)
- **ធាតុ** (ទឹក ខ្យល់ និងកម្ដៅ)
- **គណិតវិទ្យា** (ការគណនា រង្វាស់...)
- **រូបវិទ្យា** (ទម្ងន់ កម្លាំង ដែកឆក់)
- **គីមីវិទ្យា** (សមាសភាព ប្រតិកម្ម)
- **អគ្គិសនី** (ពិសោធន៍ អគ្គិសនី)
- **វិស្វកម្ម និងមេកានិច** (កង់ ការសាងសង់ ស្ពាន អគារ យន្តហោះ)
- **វិទ្យាសាស្ត្រកុំព្យូទ័រ** (ការចាប់ផ្ដើមប្រើប្រាស់ថេប្លេតជាមួយល្បែងសិក្សាគណិតវិទ្យា និងការអាន)
- **សិល្បៈ** (គំនូរ រៀនអំពីពណ៌គោល និងពណ៌បន្ទាប់បន្សំ។ល។)





*ខ្ញុំចូលចិត្តវគ្គយល់ដឹងអំពីបរិស្ថាន និងជាពិសេសសកម្មភាពសម្អាត ព្រោះវាជួយយើងរក្សាភូមិរបស់យើងឱ្យស្អាត។ ខ្ញុំអនុវត្តនូវអ្វីដែលខ្ញុំបានរៀនជាមួយបណ្ណាល័យចល័ត ដោយរក្សាផ្ទះ និងកន្លែងរស់នៅរបស់ខ្ញុំឱ្យស្អាត និងប្រើប្រាស់ប្លាស្ទិកតិចនៅផ្ទះ និងសាលារៀន។*

**យ៉ុន សីហា**
អាយុ ៩ឆ្នាំ អ្នកទទួលផលពីកម្មវិធីបណ្ណាល័យចល័ត

*ខ្ញុំចូលចិត្តអានសៀវភៅវិទ្យាសាស្ត្រ និងគណិតវិទ្យា។ តាមរយៈការអាន ខ្ញុំអាចភ្ជាប់អ្វីដែលសរសេរក្នុងសៀវភៅជាមួយនឹងមេរៀនដែលខ្ញុំទទួលក្នុងថ្នាក់ ដែលជួយខ្ញុំឱ្យយល់អំពីមុខវិជ្ជានីមួយៗកាន់តែស៊ីជម្រៅ។*

**សោម រតនា**
អាយុ១៤ឆ្នាំ សិស្សថ្នាក់ទី៧

## យោគៈ និងសមាធិ

ដើម្បីជាជំនួយដល់សុខភាពផ្លូវចិត្ត និងសុខភាពទូទៅរបស់កុមារ និងយុវជនតាមរយៈការអនុវត្តសកម្មភាពយោគៈ និងសមាធិ ៖

**អត្ថប្រយោជន៍ ៖**

- ជំនួយដល់ការផ្ដោតអារម្មណ៍លើការសិក្សា
- កាត់បន្ថយភាពតានតឹង និងការថប់បារម្ភ
- ជំនួយដង្ហើម បង្កើនថាមពល និងភាពរឹងមាំ
- ជួយឱ្យមានអាកប្បកិរិយាវិជ្ជមាន
- ជួយឱ្យមានភាពបត់បែន និងកម្លាំងសាច់ដុំ
- ស្វែងយល់ពីភាពសប្បុរស និងការយល់ចិត្តក្នុងទំនាក់ទំនងជាមួយអ្នកដទៃ



*ខ្ញុំធ្វើតាមការណែនាំអំពីការដកដង្ហើមដោយប្រុងប្រយ័ត្ន។ ពេលខ្ញុំបើកភ្នែកឡើង ខ្ញុំមានអារម្មណ៍ថា ចិត្តរបស់ខ្ញុំស្ងប់។ ក្បាច់យោគៈក៏ជួយកែលម្អស្ថានភាពរាងកាយរបស់ខ្ញុំផងដែរ។ សរុបមក ការអនុវត្តយោគៈ និងសមាធិបានធ្វើឱ្យសុខុមាលភាពផ្លូវចិត្ត និងផ្លូវកាយរបស់ខ្ញុំប្រសើរឡើង។*

**វី ស្រីនាន**
សមាជិកអង្គការសហគមន៍គោកចក

# ដៃគូរបស់អង្គការស៊ីប៉ា

## ស្ថាប័នដៃគូ

## ស្ថាប័នផ្តល់មូលនិធិ

## អ្នកឧបត្ថម្ភឯកជន និងដៃគូ

## អង្គការដៃគូសហការ

Asia Foundation, Cambodian Library Association, Cambodia Book Publishers Association, Cambodian Women for Peace and Development, Caritas Cambodia, Friends International, GMAC, IBBY, International Committee of the Red Cross, Krousar Thmey, Lycée Français René Descartes, Mith Samlanh, Mlop Tapang, NGO in Education Partnership, Passerelles numériques, Planète Enfants et Développement, Rabbit School, Room to Read, RTI, Save the Children, SVA, This Life Cambodia, Youth Star, EMDR, AZAHAR Foundation, Marins Sans Frontières, FACT

# សង្ខេបចំណាយប្រចាំឆ្នាំ២០២៣

## ចំណាយតាមកម្មវិធី (គិតជាដុល្លារ)






$ ៣៦២ ៣០០ | $ ៣៨៤ ០០០ | $ ៤៦ ១០០ | $ ១៥៨ ៨០០ | $ ៣៤៣ ៥០០ | $ ១៣២ ១០០

**សរុប ៖ $ ១ ៤២៦ ៨០០**

# ផែនការសម្រាប់ឆ្នាំ២០២៤

## កម្មវិធីតាមសាលារៀន

បន្តការសហការជាមួយនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងអប់រំ យុវជន និងកីឡាតាមរយៈវគ្គបណ្តុះបណ្តាល និងការផ្សព្វផ្សាយការអាន។

### ថ្នាក់មត្តេយ្យ

- បន្តការគាំទ្របណ្ណាល័យខ្នាតតូចក្នុងសាលាមត្តេយ្យសហគមន៍។
- បន្តរៀបចំវគ្គបណ្តុះបណ្តាលសម្រាប់គ្រូមត្តេយ្យ។

### បណ្ណាល័យបឋមសិក្សា

- បន្តប្រគល់សៀវភៅទៅបណ្ណាល័យសាលា ព្រមទាំងផ្សព្វផ្សាយអំពីសុខភាព អនាម័យ និងបរិស្ថាន។

## កម្មវិធីអប់រំ និងអំណានសម្រាប់ទាំងអស់គ្នា

### បណ្ណាល័យចល័ត

- បន្តអភិវឌ្ឍសកម្មភាពបណ្ណាល័យចល័តផ្នែកអំណាន និងបង្កើតសកម្មភាពអប់រំថ្មីៗ សម្រាប់ការអប់រំទាំងអស់គ្នា ជាពិសេសអ្នកដែលងាយរងគ្រោះបំផុត។
- ពង្រីកសកម្មភាពបណ្ណាល័យចល័តនៅតំបន់គោលដៅថ្មីក្នុងខេត្តកំពង់ធំ ជាមួយនឹងការសាងសង់ និងសម្ពោធបណ្ណាល័យទូកទី២ ដែលនៅឃុំផាត់សណ្តាយ។
- បន្តអភិវឌ្ឍសេវាអប់រំប្រធានបទផ្សេងៗដូចជា បរិស្ថាន ស្ទីម សុវត្ថិភាពចរាចរណ៍ និងបង្កើតសកម្មភាពអប់រំថ្មី។
- បង្កើត និងពង្រឹងបណ្ណាល័យខ្នាតតូច នៅតាមតំបន់មិនទាន់រៀបរយ ភូមិដាច់ស្រយាល សាលាមត្តេយ្យសហគមន៍ និងសាលារដ្ឋ។
- បង្កើតឧបករណ៍ថ្មីសម្រាប់ការតាមដានសកម្មភាពបណ្ណាល័យចល័តឱ្យកាន់តែមានប្រសិទ្ធភាព។
- សហការជាមួយមន្ទីរអប់រំខេត្ត និងដៃគូអង្គការក្រៅរដ្ឋាភិបាល ដើម្បីបង្កើតប្រសិទ្ធភាពរួមនៃគម្រោងនៅតាមខេត្ត។

### ការអប់រំនៅតាមឡដុត

- កែលម្អសកម្មភាពអប់រំសម្រាប់កុមារ និងកម្មករដែលរស់នៅតាមតំបន់ឡដុតចំនួន៣២ ដើម្បីជួយដល់ការរៀនសូត្ររបស់ពួកគេ។
- បង្កើតបណ្ណាល័យខ្នាតតូចសហគមន៍ចំនួន១០ ដែលគ្រប់គ្រងដោយអ្នកស្ម័គ្រចិត្ត និងបណ្ណាល័យសាលាថ្មីចំនួនពីរ។
- ជួយដល់ការអប់រំកុមារអាយុពី៦ ដល់ ១២ឆ្នាំ ដែលរស់នៅក្នុងតំបន់ឡដុតចំនួន៣២។
- បង្កើតកម្មវិធីអប់រំសង្គម សម្របតាមតម្រូវការរបស់ក្មេងជំទង់ក្រៅសាលា។
- បង្កើតប្រធានបទសង្គមថ្មីសម្រាប់គ្រួសារដែលរស់នៅក្នុងរោងចក្រឥដ្ឋចំនួន៣២ ដើម្បីកែលម្អការផ្លាស់ប្តូរអាកប្បកិរិយារបស់ពួកគេ។
- ធ្វើការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មាធិការជាតិសម្រាប់ការទប់ស្កាត់ពលកម្មកុមារ ដើម្បីការពារ និងអប់រំកុមារអាយុក្រោម ១៥ឆ្នាំ
- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអ្នកគ្រប់គ្រងរោងចក្រឥដ្ឋ នាយកសាលា និងមន្ត្រីពាក់ព័ន្ធ ដើម្បីសម្រួលដល់ការសម្របសម្រួលគម្រោង។

## ការអប់រំក្នុងពន្ធនាគារ

- បន្ត និងពង្រឹងសេវាប្រឹក្សាយោបល់ និងផ្តល់កម្ចីសៀវភៅនៅក្នុងពន្ធនាគារទាំង២៨។
- បង្កើតបណ្ណាល័យថ្មីពីរនៅក្នុងពន្ធនាគារចំនួនពីរ។
- បន្តរៀបចំសកម្មភាពវប្បធម៌ និងសិល្បៈនៅក្នុងពន្ធនាគារ។
- ផ្តល់ការគាំទ្រផ្នែកអប់រំដល់ថ្នាក់អក្ខរកម្ម។
- សម្របសម្រួលកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលការងារ និងពន្ធនាគារ ដើម្បីពង្រឹងកម្មវិធីនៃការរៀបចំសម្រាប់សមាហរណកម្មរបស់ជនជាប់ឃុំ។
- បង្កើតឧបករណ៍ឌីជីថល និងបណ្តុះបណ្តាលមន្ត្រីពន្ធនាគារក្នុងការគ្រប់គ្រង និងប្រើប្រាស់ NomadLab នៅក្នុងពន្ធនាគារទាំង១៣។
- បន្តគំនិតផ្តួចផ្តើមសាកល្បងនៅក្នុងមជ្ឈមណ្ឌលអប់រំពហុព័ត៌មាននៅក្នុងពន្ធនាគារចំនួនប្រាំពីរ។

## កម្មវិធីអភិវឌ្ឍន៍យុវជន

### បណ្ណាល័យ-ជ្រុងតម្រង់ទិសវិជ្ជាជីវៈ

- រៀបចំសិក្ខាសាលា រវាងបណ្ណារក្ស បុគ្គលិកពាក់ព័ន្ធ និងសមាជិកគណៈគ្រប់គ្រងនៃអនុវិទ្យាល័យទាំង១៦។
- ធានាឱ្យមានការត្រួតពិនិត្យបច្ចេកទេស នៅតាមសាលា និងតាមអ៊ីនធឺណិត ជាមួយបណ្ណារក្សនៃវិទ្យាល័យទាំង១៦។
- គាំទ្រដល់ការរៀបចំវេទិកាការងារចំនួន៣២ ( ១៦តាមសាលា និង ១៦តាមអ៊ីនធឺណិត ) នៅក្នុងវិទ្យាល័យចំនួន១៦។

### ភាពជាពលរដ្ឋសកម្មរបស់យុវជននៅមូលដ្ឋាន

- ជ្រើសរើស និងបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្តវ័យក្មេង។
- គាំទ្រការចុះឈ្មោះសមាជិកអង្គការសហគមន៍យុវជនមូលដ្ឋានថ្មីចំនួនប្រាំ។
- បំពាក់ NomadLab នៅតាមអង្គការសហគមន៍មូលដ្ឋានយុវជនចំនួន៨ និងបណ្តុះបណ្តាលសមាជិកអំពីការប្រើប្រាស់របស់ពួកគេ។
- រៀបចំវគ្គបណ្តុះបណ្តាលសម្រាប់សមាជិកអង្គការសហគមន៍យុវជនមូលដ្ឋានចំនួន២៣ អំពីការអាន ការបង្រៀន ភាពជាអ្នកដឹកនាំ និងការប្រាស្រ័យទាក់ទង ការរៀបចំព្រឹត្តិការណ៍ និងការអង្គាសប្រាក់ ការស្ម័គ្រចិត្ត ភាពជាពលរដ្ឋ ទំនាក់ទំនង និងការកសាងក្រុម សិទ្ធិកុមារ និងយេនឌ័រ បរិស្ថាន ការធ្វើចំណាកស្រុក។ល។

### ផលិតឧបករណ៍ថ្មីៗ ជាទម្រង់សៀវភៅ និងឌីជីថល

- រចនា និងបោះពុម្ពសៀវភៅតម្រង់ទិសវិជ្ជាជីវៈ និងការណែនាំអំពីការអភិវឌ្ឍខ្លួនចំនួនប្រាំ។
- បង្កើតវីដេអូអំពីការសិក្សា និងការតម្រង់ទិសវិជ្ជាជីវៈ។
- ចែកចាយសម្ភារៈបោះពុម្ពដល់សាលារៀន។

## កម្មវិធីបោះពុម្ពផ្សាយ

- បោះពុម្ពចំណងជើងថ្មីចំនួន១៧ និងបោះពុម្ពសៀវភៅឡើងវិញប្រមាណ៥០ចំណងជើង។
- បង្កើត និងបកប្រែក្រុមសៀវភៅម៉ង់ហ្គាចំនួនបួន។
- បោះពុម្ពសៀវភៅពីរចំណងជើងរបស់អ្នកឈ្នះនៃការប្រកួតប្រជែងខួបលើកទី៤០ របស់ស៊ីប៉ា។
- កែសម្រួល និងបោះពុម្ពចំណងជើងដែលសរសេរដោយក្រុមស៊ីប៉ាក្នុងក្រុមសៀវភៅលោមអារម្មណ៍។
- បង្កើតសៀវភៅស្តីពីការអភិវឌ្ឍខ្លួនសម្រាប់យុវជន។
- បកប្រែសៀវភៅរឿងរុស្ស៊ី។
- ពង្រឹងយុទ្ធសាស្ត្រផ្សព្វផ្សាយ និងលក់សៀវភៅស៊ីប៉ា។




អង្គការស៊ីប៉ានៅបារាំង

16 rue Champ Lagarde
78000 Versailles

+33 (0)1 39 02 32 52

អង្គការស៊ីប៉ានៅកម្ពុជា

#១៤៨ ( អាគារ H ) មហាវិថីព្រះនរោត្តម
ប្រអប់សំបុត្រ ៣១ ភ្នំពេញ

+៨៥៥ (០)២៣ ២១២ ៤០៧



សិទ្ធិរូបថត ៖ Laurent Jannic / Sipar
គំរូបាយការណ៍រចនាដោយ ៖ Mathieu Mazin


Sipar

www.sipar.org

www.sipar-books.com